ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

ក្រសួងមហាផ្ទៃ

ក្រសួងយុត្តិធម៌

# គោលការណ៍ណែនាំ
# ស្តីពី ការកម្រិតការប្រើប្រាស់ការសម្រុះសម្រួល
# ឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី

ឆ្នាំ២០២២

UN WOMEN

Women Peace Makers

The Asia Foundation

Australian Aid

ACCESS
Sustainable quality services for all

# មាតិកា

អារម្ភកថា
សេចក្តីថ្លែងអំណរគុណ
អត្ថន័យនិងនិយមន័យ ....................................................................... ៧
១ សេចក្តីផ្តើម ............................................................................ ១០
១.១ សាវតារ.................................................................................. ១០
១.២ គោលបំណង.............................................................................. ១១
១.៣ វិសាលភាព និង ដែនកំណត់ ................................................................ ១១
២ ការយល់ដឹងអំពីអំពើហិង្សាលើស្ត្រីនៅកម្ពុជា .............................................. ១៣
៣ ក្របខ័ណ្ឌច្បាប់ស្តីពីការសម្រុះសម្រួលវិវាទមូលដ្ឋានដែលទាក់ទងនឹងអំពើហិង្សា
ក្នុងគ្រួសារ.................................................................................. ១៧
៤ ការសម្រុះសម្រួល និងអំពើហិង្សាលើស្ត្រីនៅប្រទេសកម្ពុជា.................................. ១៩
៤.១. តើគួរប្រើការសម្រុះសម្រួល ជាការឆ្លើយតបទៅ
នឹងអំពើហិង្សាលើស្ត្រីដែរឬទេ? ............................................................. ១៩
៤.២. ការព្រួយបារម្ភអំពីការប្រើប្រាស់ការសម្រុះសម្រួល
ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ............................................................ ១៩
៤.៣. សមាសភាពអ្នកសម្រុះសម្រួល ................................................................ ២១
៤.៤. តួនាទីរបស់អ្នកសម្រុះសម្រួល................................................................. ២២
៥. គោលការណ៍សម្រុះសម្រួលក្នុងបរិបទអំពើហិង្សាលើស្ត្រី ..................................... ២៣
៦. គោលការណ៍ណែនាំ ស្តីពីនីតិវិធីសម្រាប់ការសម្រុះសម្រួលវិវាទក្នុងបរិបទនេះ........ ៣៤
៦.១. ការត្រួតពិនិត្យបឋមលើករណី មុនចាប់ផ្តើមដំណើរការសម្រុះសម្រួល .......៣៤
៦.១.១. ករណីការសម្រុះសម្រួលលើវិវាទមិនមាននីត្យានុកូលភាពនិងភាពសមស្រប............. ៣៦
៦.១.២. ករណីការសម្រុះសម្រួល វិវាទមាននីត្យានុកូលភាព និងភាពសមស្រប ............... ៣៨
៦.២. អំឡុងពេលដំណើរការសម្រុះសម្រួល .......................................................... ៤០
៦.៣. ក្រោយការសម្រុះសម្រួល...................................................................... ៤៥
ឧបសម្ព័ន្ធទី១ ៖
ទម្រង់កម្រងសំណួរត្រួតពិនិត្យបឋម

# អារម្ភកថា

គោលការណ៍ណែនាំស្ដីពី ការកម្រិតការប្រើប្រាស់ការសម្រុះសម្រួលឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី ត្រូវបានរៀបចំឡើង ដើម្បីចង្អុលបង្ហាញអំពីគោលការណ៍ និងនីតិវិធីមុនពេល អំឡុងពេល និងក្រោយពេលសម្រុះសម្រួល ក៏ដូចជានីតិវិធីបន្ត ក្នុងករណីរកឃើញថា ការសម្រុះសម្រួលមិនមានភាពស្របច្បាប់និងមិនសមស្របសម្រាប់វិវាទដែលប្ដឹងមកនោះ។ នេះគឺដើម្បីធានាថាការសម្រុះសម្រួលមិនត្រូវបានប្រើប្រាស់ខុស ធ្វើជាយន្តការជំនួសក្នុងការបន្តនិទណ្ឌភាពរបស់ជនមុខសញ្ញានោះទេ។

គោលការណ៍ណែនាំនេះ មានវិសាលភាពចំពោះរដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ ដែលរួមមាន មន្ទីរកិច្ចការនារី ការិយាល័យនីតិកម្មនិងសម្រុះសម្រួលវិវាទមូលដ្ឋាន ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម និងគណៈកម្មាធិការឃុំ-សង្កាត់ ព្រមទាំង សន្ទានការីដទៃទៀត ដែលធ្វើការដោះស្រាយវិវាទពាក់ព័ន្ធទម្រង់ណាមួយនៃករណីហិង្សាលើស្ត្រី។ គោលការណ៍ណែនាំនេះកម្រិតការសម្រុះសម្រួលវិវាទ ជាការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រីត្រឹមតែករណីបទលហុ និងរដ្ឋប្បវេណី ប៉ុណ្ណោះ ដែលស្របតាមតួនាទី និងភារកិច្ចរបស់អាជ្ញាធរពាក់ព័ន្ធ និងស្របតាមនីតិវិធីច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ។

អំពើហិង្សាលើស្ត្រីមានច្រើនទម្រង់ នៅក្នុងប្រទេសកម្ពុជា។ អំពើហិង្សាទាំងនោះរួមមាន អំពើហិង្សាផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ច ដែលអំពើហិង្សាទាំងនោះអាចកើតមានទាំងនៅក្នុងផ្ទះ នៅកន្លែងធ្វើការ និងក្នុងសហគមន៍។ អំពើហិង្សានេះ រួមបញ្ចូលទាំងការជួញដូរមនុស្ស ការរំលោភសេពសន្ថវៈ ការបៀតបៀនផ្លូវភេទ អំពើហិង្សាលើកុមារ និងអំពើហិង្សាដោយដៃគូស្និទ្ធស្នាល។ យោងតាមការអង្កេតថ្នាក់ជាតិស្ដីពី សុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រី ឆ្នាំ២០១៥ បានរកឃើញថា ស្ត្រីដែលមានអាយុពី១៥ ដល់៦៥ឆ្នាំ ចំនួន ១នាក់ ក្នុងចំណោម ៥នាក់ ដែលធ្លាប់រៀបការឬមានទំនាក់ទំនងស្នេហាបានរាយការណ៍ថា ធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ និង/ផ្លូវភេទពីដៃគូស្នេហាក្នុងមួយជីវិតរបស់ពួកគេ។ ហើយក្នុងចំណោមស្ត្រី ៤នាក់ ដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទពីដៃគូរបស់ខ្លួន គឺ មាន៣នាក់ ធ្លាប់ទទួលរងអំពើធ្ងន់ធ្ងរ។ ទន្ទឹមនឹងនេះការអង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា ឆ្នាំ ២០១៤ បានបង្ហាញថា ស្ត្រីប្រមាណ ៤៩% យល់ថាប្ដីឬដៃគូ អាចវាយប្រពន្ធបាន បើគាត់មានហេតុផលណាមួយ ដូចជា ទៅណាមិនបានប្រាប់ មើលកូនមិនដិតដល់ ឬបដិសេធរួមភេទជាមួយគាត់ ។

ប្រទេសកម្ពុជាមានក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាតិសម្រាប់កិច្ចការពារសិទ្ធិស្ត្រី និងក្មេងស្រី មានលក្ខណៈល្អប្រសើរដើម្បីឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា មានជាអាទិ៍ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់អន្តរជាតិ ច្បាប់ជាតិ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រ នារី រតនៈទី៥ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣ និងឯកសារគតិយុត្ត ជាច្រើនទៀត។ ប៉ុន្តែការអនុវត្តច្បាប់ គោលនយោបាយ និងឯកសារគតិយុត្តទាំងនេះនៅមានកម្រិតនៅឡើយ ហើយអំពើហិង្សាលើស្ត្រី និងក្មេងស្រី នៅតែបន្តកើតមាននៅក្នុងប្រទេសកម្ពុជា ដោយមិនប្រកាន់ថាអ្នកមាន ឬអ្នកក្រនោះឡើយ ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ ឬការឈឺចាប់ផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្នែកជីវភាពសេដ្ឋកិច្ច ដែលនាំឱ្យមានការខាតបង់ថវិកា ដោយថវិកាទាំងនេះត្រូវបានចំណាយលើ សេវាសុខភាព ការបាត់បង់ផលិតភាព ជម្រកសុវត្ថិភាពសម្រាប់ស្ត្រីរងគ្រោះនិងកូនៗ សេវាសង្គមកិច្ចដើម្បីស្តារនីតិសម្បទាស្ត្រីរងគ្រោះ សេវាច្បាប់ និងសេវាចាំបាច់ផ្សេងៗទៀត ដើម្បីគាំទ្រជនរងគ្រោះ។

ការលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី នៅតែជារបៀបវារៈអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីអភិវឌ្ឍធនធានមនុស្ស និងកិច្ចអភិវឌ្ឍជាតិប្រកបដោយបរិយាបន្ននិងចីរភាព ដែលបញ្ហានេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងយុទ្ធសាស្ត្រចតុកោណនៅគ្រប់ដំណាក់កាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិជាច្រើន។ កាលពីចុងឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តជាផ្លូវការនូវផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០១៩-២០២៣ បានខិតខំប្រឹងប្រែងដាក់ឱ្យដំណើរការនូវយន្តការ គោលការណ៍ណែនាំ និងការពង្រឹងសមត្ថភាពសម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ទាំងឡាយខាងលើ ដើម្បីការពារស្ត្រី និងក្មេងស្រីពីអំពើហិង្សាឱ្យស្របតាមតម្រូវការរបស់ពួកគេ និងការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ប្រកបដោយបរិយាបន្ន។

ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ បានរួមសហការគ្នាយ៉ាងសកម្ម និងដោយភាពទទួលខុសត្រូវខ្ពស់ រៀបចំគោលការណ៍ណែនាំស្តីពី ការកម្រិតការប្រើប្រាស់ការសម្រុះសម្រួលឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រីនេះឡើង ក្នុងគោលបំណងក្នុងការប្រើប្រាស់ធ្វើជាធនធានបន្ថែមទៅលើឯកសារសម្រុះសម្រួលនានាដែលមានស្រាប់ ហើយផ្តោតសំខាន់ទៅលើ ថាតើការសម្រុះសម្រួល

ជាការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី អាចកម្រិតឱ្យប្រើប្រាស់បាននៅពេលណា និងដោយរបៀបណា ដើម្បីធានានូវគោលការណ៍នីត្យានុកូលភាព និងភាពសមស្របដែលការពារសិទ្ធិ និងសុវត្ថិភាពរបស់ស្ត្រីរងគ្រោះជាចម្បង ដូចមានចែងក្នុងយុទ្ធសាស្ត្រទី២ នៃផែនសកម្មភាពជាតិស្តីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ ២០១៩-២០២៣ ដើម្បីចូលរួមឆ្លើយតបចំពោះអំពើហិង្សាក្នុងគ្រួសារត្រឹមតែករណីបទលហុ និងរដ្ឋប្បវេណី ដោយស្របតាមតួនាទី និងភារកិច្ចរបស់អាជ្ញាធរពាក់ព័ន្ធ និងស្របតាមនីតិវិធីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ជាពិសេសគោលការណ៍ណែនាំនេះ ជាឧបករណ៍មួយដ៏មានសារៈសំខាន់ ជួយឱ្យអ្នកផ្តល់សេវាពាក់ព័ន្ធ បានយល់ដឹងកាន់តែទូលំទូលាយ អំពីគោលកបំណង វិសាលភាព សមាសភាព តួនាទី ភារកិច្ចរបស់អ្នកសម្រុះសម្រួល និងជំហាននៃដំណើរការសម្រុះសម្រួល ជាពិសេសបញ្ជ្រាបយេនឌ័រក្នុងដំណើរការសម្រុះសម្រួល ដោយផ្តោតជនរងគ្រោះជាអាទិភាព។

កាលពីឆ្នាំ២០១៨ ក្រុមការងារក្រសួងកិច្ចការនារី សហការជាមួយទីប្រឹក្សាជំនាញអន្តរជាតិ ដោយមានការគាំទ្រពីអង្គការ UNWomen បានរៀបចំឱ្យមានសេចក្តីព្រាងគោលការណ៍ណែនាំ និងមានកិច្ចប្រជុំជាច្រើនដងជាមួយក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ខេត្តព្រះសីហនុ និងកំពង់ស្ពឺ។ នៅឆ្នាំ២០២១ ក្រុមការងារក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ រួមកិច្ចសហការជាមួយអង្គការ UNWomen និងអង្គការនារីដើម្បីសន្តិភាព (WPM) តាមរយៈអង្គការមូលនិធិអាស៊ី (TAF) ដោយមានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី (DFAT) តាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ហៅកាត់ថា កម្មវិធី ACCESS បានធ្វើការពិនិត្យ និងកែសម្រួលលើខ្លឹមសារគោលការណ៍ណែនាំស្តីពី ការកម្រិតការប្រើប្រាស់ការសម្រុះសម្រួលឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី ឡើងវិញ ព្រមទាំងបានរៀបចំសៀវភៅបណ្តុះបណ្តាល និងផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ដល់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី និងមន្ត្រីអង្គការដៃគូនៃកម្មវិធី ACCCESS។

ក្រសួងកិច្ចការនារី សូមអរគុណក្រុមការងារបច្ចេកទេសក្រសួងកិច្ចកានារី ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ អង្គការនារីដើម្បីសន្តិភាព និងអង្គការ UNWomen ដែលបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសក្នុងការពិនិត្យ និងកែសម្រួលលើខ្លឹមសារនៃគោលការណ៍ណែនាំនេះ ដើម្បីឱ្យស្របទៅនឹងភាពចាំបាច់ក្នុងការឆ្លើយតបទៅនឹងតម្រូវការជនរងគ្រោះ សម្រាប់កម្មវិធីអភិវឌ្ឍន៍សមត្ថភាពមន្ត្រី/

ភ្នាក់ងារនគរបាលយុត្តិធម៌របស់ក្រសួងកិច្ចការនារី មន្ទីរកិច្ចការនារី និងអ្នកផ្តល់សេវាពាក់ព័ន្ធ ជាពិសេស សូមថ្លែងអំណរគុណ លោកជំទាវ ថ្នាក់ដឹកនាំទទួលបន្ទុកដែលបានផ្តល់ការគាំទ្រ និងជំរុញដំណើរការនៃរៀបចំគោលការណ៍ណែនាំនេះ ឱ្យទទួលបានជោគជ័យ ។

ក្រសួងកិច្ចការនារី សូមអរគុណចំពោះអង្គការមូលនិធិអាស៊ី (TFA) កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ហៅកាត់ថា កម្មវិធី AC-CESS ក្រោមជំនួយឧបត្ថម្ភពីរដ្ឋាភិបាលអូស្ត្រាលី (DFAT) សម្រាប់ផ្តល់កិច្ចគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ដំណើរការក្នុងការរៀបចំ និងបោះពុម្ពគោលការណ៍ណែនាំនេះ ។

ក្រសួងកិច្ចការនារីមានជំនឿ និងសេចក្តីសង្ឃឹមយ៉ាងមុតមាំថា គោលការណ៍ណែនាំរៀបចំគោលការណ៍ណែនាំស្តីពី ការកម្រិតការប្រើប្រាស់ការសម្រុះសម្រួលឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រីនេះ នឹងផ្តល់ការណែនាំតម្រង់ទិសដល់អ្នកផ្តល់សេវាពាក់ព័ន្ធដែលធ្វើការក្នុងវិស័យនេះ ធ្វើការអនុវត្តការងារ និងធ្វើការដោះស្រាយវិវាទពាក់ព័ន្ធទម្រង់ណាមួយនៃករណីហិង្សាលើស្ត្រី ឱ្យកាន់តែមានប្រសិទ្ធភាព និងស្របតាមតួនាទី និងភារកិច្ចរបស់អាជ្ញាធរពាក់ព័ន្ធ និងស្របតាមនីតិវិធីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ។ គោលការណ៍ណែនាំនេះ នឹងក្លាយជាឧបករណ៍ដ៏មានសារៈប្រយោជន៍បំផុត សម្រាប់ជាជំនួយស្មារតីក្នុងការផ្តល់សេវាជួយដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រឱ្យកាន់តែមានប្រសិទ្ធភាព និងប្រកបដោយបរិយាបន្នថែមទៀត ព្រមទាំងធានាភាពសុខដុមរមនា ជូនប្រជាជនកម្ពុជាផងដែរ។

ថ្ងៃ ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

# អត្ថន័យ និងនិយមន័យ

**អំពើហិង្សាលើស្ត្រី** សំដៅលើសកម្មភាពទាំងឡាយនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលធ្វើឱ្យ ឬ អាចធ្វើឱ្យមានគ្រោះថ្នាក់ ឬ រងទុក្ខលើរូបរាងកាយ ផ្លូវភេទ ផ្លូវចិត្ត និង/ឬ ផ្លូវសេដ្ឋកិច្ចចំពោះស្ត្រី។ សកម្មភាពទាំងនោះ រួមមាន ការគំរាមកំហែង ការបង្ខិតបង្ខំ ឬ ការដកហូតសិទ្ធិសេរីភាព ហើយអាចកើតមាននៅទីសាធារណៈ ឬក្នុងជីវិតឯកជន។ បុព្វហេតុចម្បងនៃអំពើហិង្សាលើស្ត្រី ត្រូវបានទទួលស្គាល់ទូទាំងពិភពលោកថា បណ្តាលមកពីវិសមភាពនៃអំណាច និងការរើសអើងយេនឌ័រ។ ពាក្យថា "ស្ត្រី" នៅទីនេះ មានន័យគ្របដណ្តប់ទាំងបុគ្គលដែលកំណត់អត្តសញ្ញាណខ្លួនឯង ឬ ត្រូវបានចាត់ទុកថាជា ស្ត្រី។

អំពើហិង្សាលើស្ត្រី គឺជាទម្រង់មួយនៃការរើសអើងលើស្ត្រី ហើយជាការរំលោភបំពានលើសិទ្ធិរបស់ស្ត្រីផងដែរ។ អំពើហិង្សាលើស្ត្រីមានបួនប្រភេទដូចខាងក្រោម៖

- អំពើហិង្សាលើរាងកាយដូចជាទះកំផ្លៀង វាយទាត់ធាក់ និងវាយដំ បង្ករបួសស្នាមដល់ស្ត្រី។ល។
- អំពើហិង្សាផ្លូវភេទ រួមមាន ការរួមភេទដោយបង្ខំ និងការបង្ខិតបង្ខំផ្លូវភេទផ្សេងៗ
- ការរំលោភបំពានខាងផ្លូវចិត្ត ដូចជា ការជេរប្រមាថ ការមើលងាយ ការបន្ទាបបន្ថោកជាប្រចាំ ការបំភិតបំភ័យ (ឧទាហរណ៍ការបំផ្លាញរបស់របរ) ការគំរាមកំហែង ការគំរាមដកហូតយកកូនៗ។ ឥរិយាបថត្រួតត្រា រួមទាំង ការដាក់ឱ្យដាច់ដោយឡែកឃ្លាតឆ្ងាយពីក្រុមគ្រួសារ និងមិត្តភក្តិ ការតាមដានរាល់សកម្មភាពគ្រប់ពេលវេលា ការស៊ីបន្ទោស ការប្រចណ្ឌនិង
- អំពើហិង្សាផ្នែកសេដ្ឋកិច្ច ដូចជា ការរឹតត្បិតការទទួលបានធនធានហិរញ្ញវត្ថុ ការងារ ការអប់រំ ឬ ការថែទាំសុខភាព

**អំពើហិង្សាក្នុងគ្រួសារ** សំដៅដល់អំពើហិង្សាដែលកើតមាន និងអាចកើតមានទៅលើប្តី ឬប្រពន្ធ កូនក្នុងបន្ទុក និងជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះនិងក្នុងបន្ទុកគ្រួសារ។

**អំពើហិង្សាពីដៃគូស្និទ្ធស្នាល** សំដៅដល់ឥរិយាបថទាំងឡាយណាក្នុងទំនាក់ទំនងស្និទ្ធស្នាល ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់រូបរាងកាយ ផ្លូវចិត្ត ផ្លូវភេទ និង សេដ្ឋកិច្ចរបស់ភាគីទាំងឡាយនៃទំនាក់ទំនងនេះ។ អំពើហិង្សាពីដៃគូសិទ្ធស្នាល គឺជាទម្រង់មួយនៃអំពើប្រឆាំងនឹងស្ត្រីភេទនិងរួមបញ្ចូលទម្រង់នៃអំពើហិង្សាដូចមានរៀបរាប់និយមន័យខាងលើនៃអំពើហិង្សាលើស្ត្រី។

**ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** សំដៅទៅលើកិច្ចនៃដំណើរការដែលត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយទំនាស់ដែលជាធម្មតាធ្វើឡើងនៅក្រៅប្រព័ន្ធតុលាការ ឬ ជាជម្រើសជំនួស ឬ ធ្វើមុនពេលនីតិវិធីនៃប្រព័ន្ធតុលាការ។ កិច្ចនៃដំណើរការនេះរួមមាន ការសម្រុះសម្រួល (សន្ធានកម្ម) ការផ្សះផ្សា អាជ្ញាកណ្តាល(មជ្ឈត្តកម្ម) ការស្តារយុត្តិធម៌ឡើងវិញ ក៏ដូចជាយន្តការក្រៅប្រព័ន្ធតុលាការផ្សេងទៀត ដែលមានលក្ខណៈបែបប្រពៃណី ទំនៀមទម្លាប់ ឬ សាសនា។

**ការសម្រុះសម្រួល (ឬសន្ធានកម្ម)** គឺជាដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមួយប្រភេទ ដែលធ្វើឡើងដោយសម្ងាត់និងការស្ម័គ្រចិត្តរបស់ភាគី ហើយសម្របសម្រួលដោយអ្នកសម្រុះសម្រួល ដែលទទួលបានការបណ្តុះបណ្តាលនិងមានអព្យាក្រឹតភាព។ នៅពេលដែលសមរម្យ អ្នកសម្រុះសម្រួលជួយដល់ភាគីក្នុងការកំណត់តម្រូវការរបស់ពួកគេ និងស្វែងរកជម្រើសជាក់លាក់ ដើម្បីឈានទៅរកកិច្ចព្រមព្រៀងមួយដែលបំពេញនូវតម្រូវការរបស់ភាគីទាំងពីរ។ ភាគីវិវាទ ជាអ្នកគ្រប់គ្រងលើលទ្ធផលនៃការសម្រុះសម្រួល ហើយអ្នកសម្រុះសម្រួលគ្រាន់តែជាអ្នកគ្រប់គ្រងលើដំណើរការសម្រុះសម្រួល ដោយមិនមានបំណងទុកជាមុនក្នុងការជំរុញឱ្យភាគីទាំងពីរថែរក្សាជីវិតគ្រួសារ ឬ ផ្តល់ជាមតិយោបល់ណាមួយទៅដល់ភាគីវិវាទនោះទេ។ នៅពេលដែលភាគីវិវាទគិតថាមិនចង់ឈានទៅដល់កិច្ចព្រមព្រៀងទេ ពួកគេមានសេរីភាពក្នុងការងាកទៅរកជម្រើសផ្សេងទៀត រួមទាំងការប្តឹងទៅតុលាការ។

**ការផ្សះផ្សា** ក្នុងបរិបទវិវាទក្នុងគ្រួសារ ការផ្សះផ្សាគឺជាដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមួយប្រភេទដោយស្ម័គ្រចិត្ត ដែលធ្វើឡើងដោយអ្នកផ្សះផ្សាមិនលំអៀង និងក្នុងគោលបំណងគិតទុកជាមុនក្នុងការធ្វើឱ្យភាគី ទាំងពីររស់ជា នឹងគ្នាវិញក្នុងជីវិតគ្រួសារ។

**អាជ្ញាកណ្តាល (មជ្ឈត្តកម្ម)** គឺជាដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមួយប្រភេទដែលធ្វើឡើងដោយភាគីទីបីអព្យាក្រឹត (អាជ្ញាកណ្តាល) ដែលមានសិទ្ធិសម្រេចចិត្ត និងវិនិច្ឆ័យរកខុសត្រូវក្នុងវិវាទបន្ទាប់ពីទទួលបាន ភស្តុតាង ឬ ស្តាប់ការជជែកវែកញែកពីភាគីទាំងពីររួចមក។

**ការស្តារយុត្តិធម៌ឡើងវិញ** គឺជាដំណើរការមួយដែលស្ត្រីរងគ្រោះ និងជនមុខសញ្ញា ក្រុមគ្រួសាររបស់ពួកគេ និង អ្នកតំណាងសហគមន៍ សុទ្ធតែចូលរួមដោយផ្ទាល់ក្នុងការឆ្លើយតបទៅនឹងការខូចខាតដែលបង្កឡើងដោយសកម្មភាពរបស់ជនមុខសញ្ញា។ សម្រាប់គំរូនៃការស្តារយុត្តិធម៌ឡើងវិញមួយចំនួន ជនមុខសញ្ញា ត្រូវបានរំពឹងទុកថានឹងទទួលខុសត្រូវចំពោះការប្រព្រឹត្តបទល្មើសរបស់ខ្លួន ដើម្បីជាលក្ខខណ្ឌអាចចូលរួមក្នុងដំណើរការនេះបាន។

**អ្នកអម ឬ អ្នកគាំទ្រ** (ក្នុងដំណើរការសម្រុះសម្រួល) សំដៅដល់អ្នកផ្តល់ការគាំទ្រផ្នែកផ្លូវចិត្ត និងផ្នែកសីលធម៌ដល់ភាគីវិវាទ ឬ ជួយភាគីឱ្យយល់អំពីដំណើរប្រព្រឹត្តទៅនៃការសម្រុះសម្រួល។ អ្នកអម ឬ អ្នកគាំទ្រ ត្រូវជាបុគ្គលមិនពាក់ព័ន្ធនឹងវិវាទ មិនទទួលបានផលប្រយោជន៍ចេញពីលទ្ធផលនៃការសម្រុះសម្រួល និងជាពិសេស មិនកាន់តែធ្វើឱ្យមានវិសមភាពនៃអំណាចក្នុងដំណើរការសម្រុះសម្រួលឡើយ។ ជាងនេះទៅទៀត អ្នកអម ឬ អ្នកគាំទ្រ ត្រូវតែគោរពតាមគោលការណ៍រក្សាការសម្ងាត់។ អ្នកអម ឬ អ្នកគាំទ្រ អាចអង្គុយអមភាគីវិវាទ ប៉ុន្តែមិនអាចផ្តល់មតិយោបល់ ឬ ចូលរួមសកម្មក្នុងដំណើរការសម្រុះសម្រួលឡើយ។ អ្នកអម ឬ អ្នកគាំទ្រ អាចស្នើសុំឱ្យផ្អាកដំណើរការសម្រុះសម្រួល ក្នុងករណីដែលភាគីវិវាទទំនងជាមានអារម្មណ៍ស្មុគស្មាញ ឬ មិនយល់ពីដំណើរការនៃការសម្រុះសម្រួល។ អ្នកសម្រុះសម្រួលអាចដក អ្នកអម ឬ អ្នកគាំទ្រដែលបង្កការរំខាន ឬ បង្អាក់ដំណើរការសម្រុះសម្រួលចេញពីការសម្រុះសម្រួលបាន ប៉ុន្តែភាគីក៏អាចមានជម្រើសក្នុងការស្នើឱ្យមានការលើកពេលកិច្ចប្រជុំសម្រុះសម្រួល ដើម្បីខ្លួនអាចជ្រើសរើសអ្នកអម ឬ អ្នកគាំទ្រផ្សេងទៀតជំនួសវិញ។ ភាគីវិវាទដែលត្រូវការអ្នកអម ឬ អ្នកគាំទ្រ គឺត្រូវតែជាជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី ដែលមានភាពភ័យខ្លាចឬក្តីបារម្ភអំពីការសម្រុះសម្រួល ឬ អ្នកមានពិការភាពរាងកាយ ឬ ស្មារតី ដែលកត្តាទាំងនេះអាចជាឧបសគ្គដល់ពួកគេក្នុងការយល់ ឬ ចូលរួមក្នុងដំណើរការសម្រុះសម្រួលឱ្យបានពេញលេញ និងមានអត្ថន័យ។ ភាគីវិវាទអាចជ្រើសរើសបុគ្គល អព្យាក្រឹតណាមួយធ្វើជាអ្នកអម ឬ អ្នកគាំទ្ររបស់ខ្លួនបាន ដូចជា មិត្តភក្តិ សាច់ញាតិ បុគ្គលិកសង្គម មន្ត្រីអង្គការមិនមែនរដ្ឋាភិបាល ឬ បុគ្គលផ្សេងទៀតដែលភាគីស្ត្រីជឿទុកចិត្ត។ អ្នកអម ឬ អ្នកគាំទ្រ មិនគួរព្យាយាមដើរតួតំណាងឱ្យភាគីវិវាទដូចមេធាវីឡើយ។

# ១ សេចក្តីផ្តើម

## ១.១ សាវតារ

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅមូលដ្ឋាន គឺជាការអនុវត្តដែលចាក់ឫសយ៉ាងមាំនៅក្នុងយន្តការយុត្តិធម៌បែបប្រពៃណី ឬ ក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា និងត្រូវបានអនុញ្ញាតដោយច្បាប់នៅក្នុងប្រទេសកម្ពុជាក្នុងការដោះស្រាយប្រភេទវិវាទមួយចំនួននៅមូលដ្ឋាន។ មាត្រា៩២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌឆ្នាំ២០០៨ បានចែងថា "ក្រុមប្រឹក្សាត្រូវសម្រុះសម្រួលដោះស្រាយវិវាទនៅមូលដ្ឋានដោយផ្អែកតាមលក្ខណៈដែលអាចទទួលយកបានដោយភាគីនៅក្នុងវិវាទទាំងសងខាង"។ នៅក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥ ការសម្រុះសម្រួលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងលក្ខខណ្ឌមានកម្រិត។ ខណៈពេលដែលមានដំណោះស្រាយ ឬ សំណងនៅក្នុងប្រព័ន្ធតុលាការយុត្តិធម៌ ដែលស្ត្រីរងគ្រោះដោយអំពើហិង្សាពីដៃគូស្និទ្ធស្នាល អាចប្រើប្រាស់ដើម្បីស្វែងរកការដោះស្រាយបាន ស្ត្រីរងគ្រោះភាគច្រើនមិនបានជ្រើសរើសប្រើប្រព័ន្ធតុលាការយុត្តិធម៌ដោយសារកត្តារារាំងផ្សេងៗគ្នា ដូចជា កត្តាភូមិសាស្ត្រ ការចំណាយថវិកា ការមាក់ងាយពីសង្គម ការភ័យខ្លាច ការប្រឈមមុខការសងសឹក កង្វះលទ្ធភាពទទួលបានព័ត៌មាននិងសេវាច្បាប់ និងភាពមិនងាយស្រួលជាទូទៅក្នុងប្រព័ន្ធយុត្តិធម៌ចំពោះស្ត្រីរងគ្រោះដោយអំពើហិង្សា។ កត្តាទាំងនេះ គឺជាមូលហេតុមួយចំនួន ដែលធ្វើឱ្យស្ត្រីរងគ្រោះមិនបានព្យាយាមទៅទទួលយកសេវាពីប្រព័ន្ធតុលាការ។

ទោះបីជាវាមានភាពស្របច្បាប់ក្នុងករណីខ្លះក៏ដោយ ការប្រើប្រាស់យន្តការសម្រុះសម្រួលក្នុងករណីដែលវិវាទនោះអាចមានពាក់ព័ន្ធនឹងទម្រង់ណាមួយនៃអំពើហិង្សាលើស្ត្រី រួមទាំងអំពើហិង្សាក្នុងគ្រួសារ និង/ឬដោយដៃគូស្និទ្ធស្នាល នៅតែជាកង្វល់ និងមានហានិភ័យខ្ពស់។ នេះដោយសារ អំពើហិង្សាលើស្ត្រី គឺជាការរំលោភបំពានសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរដែលរឹតត្បិតសិទ្ធិជាមូលដ្ឋាន និងសេរីភាពរបស់ស្ត្រី ហើយប៉ះពាល់ដល់សន្តិសុខរបស់ស្ត្រីទាំងនៅក្នុងផ្ទះ និងក្រៅផ្ទះ ព្រមទាំងជាឧបសគ្គរារាំងដ៏ធ្ងន់ធ្ងរមួយសម្រាប់កិច្ចអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពរបស់ប្រទេសកម្ពុជា។ ដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបប្រកបដោយប្រសិទ្ធភាព ចំពោះអំពើហិង្សាលើស្ត្រី រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការ

សំខាន់ៗជាច្រើន រួមមាន ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨ និង ២០១៩-២០២៣ ផងដែរ។ ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣នេះ រួមមាន យុទ្ធសាស្ត្រជាអាទិភាពចំនួន ៤ គឺ៖ ការបង្ការទប់ស្កាត់ កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ ការបង្កើតនិងការអនុវត្តគោលនយោបាយនិងច្បាប់ និងការពិនិត្យតាមដាននិងការវាយតម្លៃ។ អាទិភាពចម្បងមួយ គឺការបង្កើតបទដ្ឋាននិងគោលការណ៍ណែនាំសម្រាប់ការការពារ និងការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី ដែលជាមូលដ្ឋានគ្រឹះនៃការបង្កើតគោលការណ៍ណែនាំនេះឡើង។

## ១.២ គោលបំណង

គោលការណ៍ណែនាំនេះ មានគោលបំណងក្នុងការប្រើប្រាស់ធ្វើជាធនធានបន្ថែមទៅលើឯកសារសម្រុះសម្រួលនានាដែលមានស្រាប់ ហើយផ្តោតសំខាន់ទៅលើ ថាតើការសម្រុះសម្រួលជាការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី អាចកម្រិតឱ្យប្រើប្រាស់បាននៅពេលណា និងដោយរបៀបណា ដើម្បីធានានូវគោលការណ៍នីត្យានុកូលភាព និងភាពសមស្របដែលការពារសិទ្ធិ និងសុវត្ថិភាពរបស់ស្ត្រីរងគ្រោះ ជាចម្បង។

## ១.៣ វិសាលភាព និង ដែនកំណត់

គោលការណ៍ណែនាំនេះ មានវិសាលភាពចំពោះរដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងរដ្ឋបាលឃុំ-សង្កាត់ ដែលរួមមាន មន្ទីរកិច្ចការនារី ការិយាល័យនីតិកម្មនិងសម្រុះសម្រួលវិវាទមូលដ្ឋាន ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម និងគណៈកម្មាធិការឃុំ-សង្កាត់ពាក់ព័ន្ធ ព្រមទាំង អ្នកផ្តល់សេវាដោះស្រាយវិវាទទាំងក្នុងវិស័យឯកជន និងសង្គមស៊ីវិល។ គោលការណ៍ណែនាំនេះ កម្រិតការសម្រុះសម្រួលវិវាទជាការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រីត្រឹមតែករណីបទលហុ និងរដ្ឋប្បវេណីប៉ុណ្ណោះ ដែលស្របតាមតួនាទី និងភារកិច្ចរបស់អាជ្ញាធរពាក់ព័ន្ធ និងស្របតាមនីតិវិធីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ។

គោលការណ៍ណែនាំនេះ នឹងចង្អុលបង្ហាញអំពីគោលការណ៍ និងនីតិវិធីមុនពេល អំឡុងពេល និងក្រោយពេលសម្រុះសម្រួល ក៏ដូចជានីតិវិធីបន្ត ក្នុងករណីរកឃើញថា ការសម្រុះសម្រួលមិនមានភាពស្របច្បាប់និងមិនសមស្របសម្រាប់វិវាទដែលប្តឹងមកនោះ។ នេះគឺដើម្បីធានាថាការសម្រុះសម្រួលមិនត្រូវបានប្រើប្រាស់ខុស ធ្វើជាយន្តការជំនួសក្នុងការបន្តនិទណ្ឌភាពរបស់ជនមុខសញ្ញានោះទេ។

ទោះបីជាក្នុងករណីបទលហុ និងរដ្ឋប្បវេណីក៏ដោយ ការសម្រុះសម្រួលមិនអាចត្រូវបានធ្វើឡើងជាដាច់ខាតនៅពេលដែល៖

- មានប្រវត្តិនៃការរំលោភបំពានម្តងហើយម្តងទៀតមកលើស្ត្រីរងគ្រោះដោយជនមុខសញ្ញាមុខដដែល។ ក្នុងករណីបែបនេះ ការសម្រុះសម្រួលអាចបង្កឱ្យមានការសងសឹក និងអន្តរាយដល់ស្ត្រីរងគ្រោះ។
- ក្នុងករណីដែលកំណត់ច្បាស់ថាការអនុវត្ត ឬ បន្តដំណើរការសម្រុះសម្រួលនេះ អាចបង្កគ្រោះថ្នាក់ដល់សុវត្ថិភាព និងសន្តិសុខរបស់ស្ត្រីរងគ្រោះ ឬ បណ្តាលឱ្យនាងទទួលអំពើហិង្សាថែមទៀត។
- ស្ត្រីរងគ្រោះត្រូវបានជនមុខសញ្ញា ឬ នរណាម្នាក់ផ្សេងទៀត គំរាមគំហែង ហើយវាធ្វើឱ្យស្ត្រីមិនអាច/មិនហ៊ានធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯងបាន។
- នៅពេលដែលជនមុខសញ្ញាជាអ្នកប្រព្រឹត្តបទល្មើសម្តងហើយម្តងទៀត ហើយមានកិច្ចព្រមព្រៀងដោះស្រាយគ្នាពីមុនដែលជនមុខសញ្ញាបានបំពានម្តងហើយម្តងទៀតស្របតាមមាត្រា៣៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។
- វិវាទដែលពាក់ព័ន្ធនឹង ឬ អាចបង្កគ្រោះថ្នាក់ដល់កុមារ។
- ភាគីណាម្នាក់ដែលមានពិការភាពផ្នែកស្មារតី ឬ ការទន់ខ្សោយសតិបញ្ញា ដែលធ្វើឱ្យពួកគេមិនអាចស្វែងយល់ និងចូលរួមដោយពេញលេញនៅក្នុងដំណើរការសម្រុះសម្រួល។

ទោះបីជាអំពើហិង្សាក្នុងគ្រួសារ (យោងតាមច្បាប់នៃប្រទេសកម្ពុជា) មានរាប់បញ្ចូលគ្រប់វ័យក៏ដោយ គោលការណ៍ណែនាំនេះមិនរាប់បញ្ចូលករណី ក្មេងស្រី-កុមារី ដោយសារពួកគេគ្មានសមត្ថភាពផ្នែកច្បាប់ក្នុងការចូលរួមដោយខ្លួនឯងនៅក្នុងដំណើរការសម្រុះសម្រួលទេ។

# ២ ការយល់ដឹងអំពីអំពើហិង្សាលើស្ត្រីនៅកម្ពុជា

អំពើហិង្សាលើស្ត្រីមានច្រើនទម្រង់ នៅក្នុងប្រទេសកម្ពុជា។ អំពើហិង្សាទាំងនោះរួមមាន អំពើហិង្សាផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងសេដ្ឋកិច្ច ដែលអំពើហិង្សាទាំងនោះអាចកើតមានទាំងនៅក្នុងផ្ទះ នៅកន្លែងធ្វើការ និងក្នុងសហគមន៍។ បុព្វហេតុចម្បងនៃអំពើហិង្សាលើស្ត្រី បណ្តាលមកពីវិសមភាពនៃអំណាច និងការរើសអើងផ្អែកយេនឌ័រ និងត្រូវបានបន្តជំរុញឱ្យកើតមានថែមទៀតតាមរយៈបទដ្ឋានសង្គមនានា ដែលបណ្តោយឱ្យមានអំពើហិង្សា។ អំពើហិង្សានេះ រួមបញ្ចូលទាំងការជួញដូរមនុស្ស ការរំលោភសេពសន្ថវៈ ការបៀតបៀនផ្លូវភេទ អំពើហិង្សាលើកុមារ និងអំពើហិង្សាដោយដៃគូស្និទ្ធស្នាល។

ទម្រង់នៃអំពើហិង្សាទាំងនេះ មិនមែនមានទំនាក់ទំនងដាច់ដោយឡែកពីគ្នានោះទេ។ លក្ខណៈទូទៅនៃអំពើហិង្សានេះគឺចាប់ផ្តើមពីសកម្មភាពបង្ករបួសស្នាមតូចតាច បន្ទាប់មកនៅពេលដែលជនមុខសញ្ញាបង្កើនភាពជឿជាក់របស់ខ្លួន ពួកគេនឹងចាប់ផ្តើមប្រើសកម្មភាពហិង្សាកាន់តែខ្លាំងឡើង។ ប្រភេទអំពើហិង្សាជាទូទៅប្រឆាំងនឹងស្ត្រីគឺការបៀតបៀនផ្លូវភេទ និងទម្រង់នៃអំពើហិង្សាដទៃទៀតនៅទីកន្លែងធ្វើការ។ ការកើនឡើងនៃកម្រិតអំពើហិង្សានៅកន្លែងធ្វើការអាចស្តែងចេញតាមរយៈសកម្មភាពបឋមតិចតួចដូចជា ការបន្លាច ការមិនគោរព ការមិនសហការ និងការបៀតបៀនដោយពាក្យសម្តី រហូតដល់ការប្រើប្រាស់ហិង្សាជាពាក្យសម្តី ដូចជា ការគំរាមកំហែង និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ មុនពេលឈានដល់ការប្រើប្រាស់ហិង្សាលើរូបរាងកាយ។ អំពើហិង្សាដែលកើតឡើងក្នុងគ្រួសារ ក៏មានលក្ខណៈប្រហាក់ប្រហែលនឹងទម្រង់នេះដែរ ប៉ុន្តែវាជាវដ្តនៃអំពើហិង្សាដែលមានលក្ខណៈតានតឹងរួចអាចមានសភាពស្ងប់ស្ងាត់មួយរយៈមុនពេលកើនឡើងអំពើហិង្សាម្តងទៀត។

## រូបភាពទី ១ ៖ ប្រភេទអំពើហិង្សាលើស្ត្រី

### អំពើហិង្សាផ្លូវកាយ

- ការរុញ
- ការច្រាន
- ការវាយដំ
- ការទះកំផ្លៀង
- ការវាយដំដោយប្រើប្រាស់វត្ថុ
- ការគប់វត្ថុ
- សកម្មភាពផ្សេងទៀត ដើម្បីប៉ុនប៉ងធ្វើបាបស្ត្រី

### អំពើហិង្សាផ្លូវចិត្ត

- ការបន្ទោសបន្ទោកជាប្រចាំ
- ការជេរប្រមាថមើលងាយ
- ការគំរាមកំហែង
- ការប្រច័ណ្ឌខ្លាំង
- ឥរិយាបថត្រួតត្រា
- ការដាក់ឱ្យដាច់ដោយឡែកឃ្លាតឆ្ងាយពីក្រុមគ្រួសារ
- តាមដានរាល់សកម្មភាពគ្រប់ពេលវេលា

### អំពើហិង្សាផ្លូវកាយភេទ

- ការផ្តល់យោបល់ពាក់ព័ន្ធផ្លូវភេទដែលមិនទទួលបានការអនុញ្ញាត
- ការប៉ះពាល់ដែលមិនត្រូវបានអនុញ្ញាត
- ការប៉ុនប៉ងរំលោភផ្លូវភេទ
- ការបង្ខំឱ្យធ្វើសកម្មភាពផ្លូវភេទ
- ការបង្ខំឱ្យសម្រាតបង្ហាញរាងកាយ
- ការចាប់រំលោភ
- ការបង្ខំឱ្យមើលរឿងអាសអាភាស

### អំពើហិង្សាផ្នែកសេដ្ឋកិច្ច

- ការបដិសេធមិនឱ្យដៃគូគ្រប់គ្រងលើធនធានជាមូលដ្ឋាន
- ការបដិសេធមិនឱ្យថវិកា
- ការបដិសេធមិនចូលរួមវិភាគទានផ្នែកហិរញ្ញវត្ថុក្នុងបន្ទុកគ្រួសារ
- ការបដិសេធមិនឱ្យអាហារ និងតម្រូវការមូលដ្ឋាន
- ការត្រួតត្រាលើការទទួលបានការថែទាំសុខភាព និងភាពមានការងារធ្វើ

**យោងតាមការសិក្សាស្រាវជ្រាវរបស់ក្រសួងកិច្ចការនារីនៅឆ្នាំ ២០១៤ និង២០១៥ ស្ត្រីនៅប្រទេសកម្ពុជាជាទូទៅ បានរាយការណ៍ពីបទពិសោធន៍ទទួលរងអំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល ដូចខាងក្រោម៖**

- ស្ត្រីម្នាក់ក្នុងចំណោមស្ត្រី ៥នាក់ ដែលមានអាយុចន្លោះពី ១៥-៦៤ ឆ្នាំ បានរាយការណ៍ថាធ្លាប់មានបទពិសោធន៍ទទួលរងអំពើហិង្សាលើរាងកាយ និង/ឬ ផ្លូវភេទ ដោយដៃគូស្និទ្ធស្នាល

យ៉ាងហោចណាស់ម្តងក្នុងមួយជីវិតរបស់ពួកគេ។

- ស្ត្រីច្រើនជាង ៣០% ធ្លាប់មានបទពិសោធន៍ទទួលរងអំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល មកលើរាងកាយ ផ្លូវភេទ ផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ច ក្នុងជីវិតរបស់ពួកគេ។

**អំពើហិង្សាដោយដៃគូស្និទ្ធស្នាល ច្រើនតែបណ្តាលឱ្យមានរបួស និងកើតឡើងម្តងហើយម្តងទៀត**

- ស្ត្រីចំនួនបីភាគបួន ក្នុងចំណោមស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ បានរាយការណ៍ពីអំពើហិង្សាធ្ងន់ធ្ងរ។
- ស្ត្រីទទួលរងអំពើហិង្សាទាំងនេះជាញឹកញាប់ មិនមែនជាឧបទ្ទវហេតុ ម្តងម្កាលនោះទេ។

**បុរសក៏បានរាយការណ៍ អំពីការប្រព្រឹត្តអំពើហិង្សានៅពេលត្រូវបានសម្ភាសន៍**

- ៣២.៨% នៃបុរសដែលបានចូលរួមសម្ភាសន៍ ក៏បានរាយការណ៍អំពីការប្រព្រឹត្តការរំលោភបំពានលើរាងកាយ និង/ឬ អំពើហិង្សាផ្លូវភេទផងដែរ។
- ៥៤.៣% បានរាយការណ៍ថា បានប្រព្រឹត្តអំពើរំលោភបំពានផ្លូវចិត្តយ៉ាងហោចណាស់ម្តង និង
- ៥៣.១% បានសារភាពថា ខ្លួនបានប្រព្រឹត្តការរំលោភបំពានផ្នែកសេដ្ឋកិច្ចលើដៃគូស្និទ្ធស្នាលរបស់ខ្លួនជាស្ត្រី យ៉ាងហោចណាស់ម្តងក្នុងមួយជីវិតរបស់ពួកគេ។

**ស្ត្រីដែលទទួលរងអំពើហិង្សាក្នុងគ្រួសារ ជាទូទៅមិនប្រាប់នរណាម្នាក់ ហើយមិនស្វែងរកដំណោះស្រាយតាមប្រព័ន្ធតុលាការនោះទេ**

- មានស្ត្រីក្រោមពាក់កណ្តាល (៤៨.៦%) នៃស្ត្រីដែលទទួលរងនូវអំពើហិង្សា មិនបានប្រាប់នរណាម្នាក់ឡើយ។
- ប្រសិនបើពួកគេប្រាប់ ពួកគេប្រាប់ទៅឪពុកម្តាយ (២៤.៩%) បងប្អូនបង្កើត (២១.៣%) ឬ អ្នកជិតខាង (២១.៨%) ។
- ប្រសិនបើពួកគេរាយការណ៍ទៅអាជ្ញាធរ ជាទូទៅ ពួកគេរាយការណ៍ទៅអាជ្ញាធរនៅមូលដ្ឋាន (១៤.៥%) ឬ នគរបាល (១១.៩%) ។

អំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល តែងតែកើតឡើងម្តងហើយម្តងទៀត និងអាចកាន់តែអាក្រក់ទៅៗ តាមពេលវេលា ដោយគ្មានការអន្តរាគមន៍ណាមួយឡើយ។ វាក៏កើតឡើងនៅក្នុងវដ្ត ដូចដែលបានពិពណ៌នាខាងក្រោមដោយចាប់ផ្តើមពីរយៈពេលក្នុងក្តីស្រឡាញ់ បន្ទាប់មកភាពតានតឹងកើនឡើងដែលយូរៗទៅ នាំឱ្យផ្ទុះទៅជាអំពើហិង្សា។ នៅពេលវដ្តនៃហិង្សានេះ បន្តកើតឡើងម្តងហើយម្តងទៀត អំពើហិង្សាអាចនឹងកាន់តែធ្ងន់ធ្ងរនិងគ្រោះថ្នាក់ថែមទៀត។ ពេលខ្លះវដ្តនេះអាចបញ្ចប់ដោយមានការធ្វើឃាត ឬ អត្តឃាត ផងដែរសម្រាប់អ្នកខ្លះ។ យោងតាមការសិក្សាស្រាវជ្រាវរបស់ UNODC បានបង្ហាញថា ភាគច្រើននៃការធ្វើឃាតលើស្ត្រីរងគ្រោះ គឺប្រព្រឹត្តឡើងដោយដៃគូស្និទ្ធស្នាល ឬ សមាជិកគ្រួសាររបស់នាង។

### រូបភាពទី ២ ៖ វដ្តនៃអំពើហិង្សាលើស្ត្រី



# ៣ ក្របខ័ណ្ឌច្បាប់ស្ដីពីការសម្រុះសម្រួលវិវាទមូលដ្ឋានដែលទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ

ច្បាប់ និងគោលនយោបាយរបស់ប្រទេសកម្ពុជា ដែលគ្រប់គ្រងអំពើហិង្សាក្នុងគ្រួសារ គឺរួមមាន រដ្ឋធម្មនុញ្ញ ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី ព្រមទាំង អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់ទាំងឡាយនៃការរើសអើងប្រឆាំងនឹងស្ត្រី (អនុសញ្ញា ស៊ីដរ) និងអនុសាសន៍ទូទៅរបស់អនុសញ្ញានេះ។

មាត្រា១៧ និង មាត្រា២៦ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ អនុញ្ញាតឱ្យអាជ្ញាធរ ឬ បុគ្គលទីបីផ្សេងទៀត ធ្វើការសម្រុះសម្រួល ដោយមានការព្រមព្រៀងពីភាគីសងខាង តែក្នុងករណី "អំពើហិង្សាដែលប៉ះពាល់ខាងផ្លូវចិត្ត ឬ ផ្លូវជីវភាពសេដ្ឋកិច្ច ឬ បទល្មើសមជ្ឈិមស្រាល និងបទលហុ" ដោយហាមឃាត់ ការសម្រុះសម្រួលលើបទល្មើសដែលត្រូវបានចាត់ទុកថា ជាបទឧក្រិដ្ឋ ឬ "បទមជ្ឈិមធ្ងន់ធ្ងរ"។ ប៉ុន្តែ ក្រមព្រហ្មទណ្ឌកម្ពុជាបានបែងចែកបទល្មើសជាបីប្រភេទតែប៉ុណ្ណោះ គឺ បទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ ដោយមិនបានកំណត់ និងបែងចែកនិយមន័យអំពី "មជ្ឈិមធ្ងន់ធ្ងរ" និង "មជ្ឈិមស្រាល" នោះទេ។ ដោយឡែក មាត្រា៨៤ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ (ឆ្នាំ២០០៨) បានកំណត់ច្បាស់អំពីវិសាលភាពនៃការសម្រុះសម្រួលវិវាទនៅមូលដ្ឋាន ដោយមិនអនុញ្ញាតឱ្យមានការសម្រុះសម្រួលលើករណី អំពើហិង្សាក្នុងគ្រួសារដែលមានលក្ខណៈជា បទឧក្រិដ្ឋ ឬ បទមជ្ឈិម នោះទេ។ ក្នុងបរិបទនេះ ច្បាប់កម្ពុជាបានបញ្ជាក់ថា បទមជ្ឈិមមិនថាធ្ងន់ធ្ងរ ឬ ស្រាល មិនអាចយកមកធ្វើការសម្រុះសម្រួលបានឡើយ។ បន្ថែមពីនេះ ការសម្រុះសម្រួលវិវាទដែលមានពាក់ព័ន្ធនឹងទម្រង់ណាមួយនៃអំពើហិង្សាក្នុងគ្រួសារ អាចមានបញ្ហា និងហានិភ័យខ្ពស់ដល់គ្រួសារទាំងមូល។ គួរឱ្យកត់សម្គាល់ថាវាអាចធ្វើឱ្យស្ត្រីប្រឈមមុខនឹងហានិភ័យខ្ពស់ដូចជាការសងសឹក និងការប្រើប្រាស់អំពើហិង្សា ជាថ្មីម្ដងទៀត។

ក្នុងកំណត់ត្រាពន្យល់ផ្នែកច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ បានលើកឡើងថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នឹងមិនត្រូវបានអនុញ្ញាតឱ្យធ្វើឡើងនោះទេ ក្នុងអំឡុងពេលធ្វើអន្តរាគមន៍ (តាមមាត្រា ១៣ នៃច្បាប់នេះ) ប៉ុន្តែអាចធ្វើទៅបានបន្ទាប់ពីជនរងគ្រោះបានស្នើសុំដីកាការពារ (មាត្រា ២៦ និងមាត្រា២៧ នៃច្បាប់នេះ)។ បន្ថែមពីនេះ គណៈកម្មាធិការនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ទាំងឡាយនៃការរើសអើងប្រឆាំងនឹងស្ត្រីបានណែនាំក្នុងអនុសាសន៍ទូទៅលេខ ៣៥ កថាខណ្ឌ ៣២ ថា ការប្រើប្រាស់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងករណីនេះ "គួរត្រូវបានកំហិតឱ្យតឹងរ៉ឹង និងអនុញ្ញាតឱ្យតែក្នុងករណីដែលមានអ្នកជំនាញបានធ្វើការវាយតម្លៃជាមុន ដោយធានាថា ស្ត្រីទទួលបានព័ត៌មានគ្រប់គ្រាន់អំពីសិទ្ធិស្របច្បាប់របស់ពួកគេ រួមទាំងសិទ្ធិក្នុងការបន្តបណ្តឹងព្រហ្មទណ្ឌ និងគោលការណ៍នៃការយល់ព្រមដោយសេរី និងដឹងជាមុន ដោយមិនបង្កហានិភ័យដល់សុវត្ថិភាពដល់ស្ត្រី និងសមាជិកគ្រួសាររបស់នាង។ យន្តការដោះស្រាយនេះ គួរជាយន្តការដែលផ្តល់ភាពអង់អាចដល់ស្ត្រី និងត្រូវធ្វើឡើងដោយបុគ្គលដែលមានបទពិសោធន៍ និងទទួលបានការបណ្តុះបណ្តាលជំនាញយល់ដឹងអំពីយេនឌ័រគ្រប់គ្រាន់ក្នុងការអន្តរាគមន៍ការពារសិទ្ធិស្ត្រី និងកុមារ ដោយមិនមានផ្នត់គំនិតយេនឌ័រអវិជ្ជមានដែលអាចធ្វើឱ្យស្ត្រីទទួលរងអំពើហិង្សាម្តងទៀត។" អាស្រ័យហេតុនេះ ដូចមានចែងក្នុងវិសាលភាពនិងដែនកំណត់ គោលការណ៍ណែនាំនេះ ជំរុញឱ្យមានការសម្រុះសម្រួលតែក្នុងករណីបទលហុ និងរដ្ឋប្បវេណីតែប៉ុណ្ណោះ ដោយចាំបាច់ត្រូវតែអនុវត្តយ៉ាងតឹងរ៉ឹង នូវនីតិវិធីស្តង់ដារដូចមានចែងក្នុងគោលការណ៍ណែនាំនេះ និងប្រកាន់ខ្ជាប់នូវគោលការណ៍សិទ្ធិមនុស្ស ដើម្បីធានានូវសុវត្ថិភាព សមធម៌និងសមភាព និងការផ្តោតទៅលើជនរងគ្រោះជាសំខាន់។

# ៤ ការសម្រុះសម្រួល និងអំពើហិង្សាលើស្ត្រីនៅប្រទេសកម្ពុជា

## ៤.១ តើគួរប្រើការសម្រុះសម្រួល ជាការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីដែរ ឬ ទេ?

ជាទូទៅ ការប្រើប្រាស់ការសម្រុះសម្រួលក្នុងករណីអំពើហិង្សាក្នុងគ្រួសារ មិនត្រូវបានណែនាំឱ្យធ្វើឡើងនោះទេ។ អ្នកជំនាញខ្លះ មិនណែនាំឱ្យប្រើប្រាស់ការសម្រុះសម្រួលទោះក្នុងទម្រង់ហិង្សាបែបណាក៏ដោយ តែអ្នកជំនាញផ្សេងទៀត គ្រាន់តែកម្រិតការសម្រុះសម្រួលណាដែលមានចរិតលក្ខណៈ ជាការដាក់កំហិតតែប៉ុណ្ណោះ។ បន្ថែមពីនេះទៀត ចំណុចគួរឱ្យកត់សម្គាល់មួយគឺថា ដំណើរការផ្សះផ្សាមិនគួរត្រូវបានអនុវត្តសម្រាប់ជាការឆ្លើយតបទៅនឹងទម្រង់ទាំងឡាយនៃអំពើហិង្សាក្នុងគ្រួសារនោះទេ ព្រោះគោលបំណងចុងក្រោយរបស់ដំណើរការនេះត្រូវបានកំណត់ទុកមុនជាស្រេចក្នុងការបន្តថែរក្សាជីវិតគ្រួសារ ដែលបានប្រានចោលរាល់ការសម្រេចចិត្តរបស់ស្ត្រី ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងភាពម្ចាស់ការលើខ្លួនឯងរបស់ពួកគេ ហើយក្នុងករណីខ្លះទៀត វាអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិតពួកគេថែមទៀត។ ដោយឡែកក្នុងដំណើរការសម្រុះសម្រួល សេចក្តីសម្រេចចិត្តធ្វើឡើងដោយភាគីទាំងពីរផ្ទាល់ ប៉ុន្តែយន្តការនេះក៏អាចមានបញ្ហាប្រឈមផងដែរ ដែលចាំបាច់ត្រូវគោរពទៅតាមនីតិវិធី និងគោលការណ៍ស្តង់ដារសិទ្ធិមនុស្សដែលមានចែងក្នុងគោលការណ៍ណែនាំនេះឱ្យបានខ្ជាប់ខ្ជួនដែរ។

## ៤.២ ការព្រួយបារម្ភអំពីការប្រើប្រាស់ ការសម្រុះសម្រួលក្នុងករណី អំពើហិង្សាក្នុងគ្រួសារ

ជាទូទៅ ជនមុខសញ្ញានៃអំពើហិង្សាក្នុងគ្រួសារ ច្រើនតែមានអំណាចត្រួតត្រាលើស្ត្រីរងគ្រោះ។ កត្តានេះធ្វើឱ្យជនមុខសញ្ញាមានភាពងាយស្រួលក្នុងការត្រួតត្រាដំណើរការនៃការសម្រុះសម្រួលបាន។

១ ការប្រើប្រាស់ការសម្រុះសម្រួលក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីមិនត្រូវបានគណៈកម្មាធិការអនុសញ្ញា ស៊ីដរ ណែនាំឱ្យអនុវត្តនោះទេ។ ប៉ុន្តែ នៅក្នុងឆ្នាំ២០១១ ក្រុមប្រឹក្សាសហភាពអឺរ៉ុបស្តីពីអនុសញ្ញាការពារនិងប្រយុទ្ធប្រឆាំងអំពើហិង្សាលើស្ត្រីនិងហិង្សាក្នុងគ្រួសារ បានហាមឃាត់តែដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទាំងឡាយណាដែលមានលក្ខណៈជាការដាក់កំហិតប៉ុណ្ណោះ។.

ការសម្រុះសម្រួលត្រូវបានគេ សន្មតថា ជាការចរចារវាងគូភាគីស្មើភាពគ្នា ដែលអាចនិយាយដោយសុវត្ថិភាពនិងសម្រេចចិត្តដោយខ្លួនឯង ហើយអាចឈានទៅរកកិច្ចព្រមព្រៀងមួយដែលកើតឡើងដោយការស្ម័គ្រចិត្តនិងមិនមានការបង្ខិតបង្ខំ។ ដូច្នេះប្រសិនបើមានការត្រួតត្រាកើតឡើងក្នុងដំណើរការនេះការសម្រុះសម្រួលមិនមែនជាជម្រើសល្អនោះទេ។

ឧទាហរណ៍ខ្លះៗ ដែលបង្ហាញពីកាលៈទេសៈដែលស្ត្រីរងគ្រោះមិនមានអំណាចស្មើគ្នាក្នុងការចូល រួមក្នុងដំណើរការសម្រុះសម្រួលនោះគឺ នៅពេលដែលជនរងគ្រោះ (ជាធម្មតាគឺជាប្រពន្ធ) មិនអាចនិយាយដោយបើកចំហ ឬ បង្កើតជម្រើសផ្សេងៗបានក្នុងដំណើរការនៃការសម្រុះសម្រួលដោយសារមូលហេតុ ៖

- ជនមុខសញ្ញាបានប្រាប់ទៅស្ត្រីរងគ្រោះកុំឱ្យនិយាយអំពីអ្វីដែលបានកើតឡើងមុនការសម្រុះ សម្រួល ហើយជនមុខសញ្ញាជាមេគ្រួសារ និងជាអ្នកទទួលខុសត្រូវគ្រួសារ ដូច្នេះស្ត្រីរងគ្រោះអាចលាក់លៀមមិននិយាយប្រាប់ពីអំពើហិង្សាដែលកើតលើនាង។
- ស្ត្រីរងគ្រោះភ័យខ្លាចថា បើនាងនិយាយច្រើនពេក ប្ដីរបស់នាងនឹងប្រព្រឹត្តអំពើហិង្សាកាន់តែច្រើនមកលើនាងនៅពេលក្រោយ។ ក្នុងករណីខ្លះ ប្ដីរបស់នាងគំរាមវាយនាងប្រសិនបើនាងហ៊ានចែករំលែករឿងរ៉ាវច្រើនពេកទៅកាន់អ្នកដទៃ។
- ស្ត្រីរងគ្រោះពឹងផ្អែកផ្នែកហិរញ្ញវត្ថុលើ ប្ដី/ដៃគូ ហើយ ប្ដី/ដៃគូ របស់នាងបានគំរាមកំហែង ឬនាងមានការភ័យខ្លាចថា ប្ដី/ដៃគូ របស់នាងនឹងដកហូតធនធាន ប្រសិនបើនាងចែករំលែកព័ត៌មាន។
- វប្បធម៌ស៊ីបន្ទោសមកលើស្ត្រី ចំពោះការរំលោភបំពានដែលកើតឡើងលើស្ត្រីរងគ្រោះ (ដោយ សារឥរិយាបថរបស់ស្ត្រីរងគ្រោះ ទើបបណ្ដាលឱ្យមានការរំលោភបំពានកើតឡើង) ដូច្នេះបើសារភាពថាស្ត្រីរងគ្រោះត្រូវបានគេរំលោភបំពាន មានន័យថា ស្ត្រីរងគ្រោះបានធ្វើខុសបទដ្ឋានសង្គមនោះ។

សូម្បីតែអ្នកសម្រុះសម្រួលដែលមានជំនាញខ្លាំងកម្រិតណា ក៏មិនអាចលុបបំបាត់អតុល្យភាពអំណាចនេះបានទាំងស្រុងដែរ ពីព្រោះអ្នកសម្រុះសម្រួលគ្រប់គ្រងតែដំណើរនៃការសម្រុះសម្រួលតែប៉ុណ្ណោះ មិនមែនគ្រប់ពេលដែលមានរឿងកើតឡើងនៅមុន ឬ ក្រោយ ពេលប្ដីប្រពន្ធចាកចេញពីការសម្រុះសម្រួលនេះឡើយ។

ក្នុងករណីវិជ្ជមានខ្លះ ការសម្រុះសម្រួលបានអនុញ្ញាតឱ្យភាគីអនុវត្តនូវសិទ្ធិស្វ័យសម្រេច និងភាពជាម្ចាស់លើខ្លួនឯង និងផ្តល់ឱកាសក្នុងការពង្រឹងសិទ្ធិអំណាចដល់ស្ត្រីរងគ្រោះ និងបង្កើតសំណង ឬ ដំណោះស្រាយមួយ ដែលមានភាពច្នៃប្រឌិតដែលអាចធ្វើទៅបាន ជាពិសេសសមស្របនឹងតម្រូវការរបស់ស្ត្រីរងគ្រោះ។

ខាងក្រោមជាឧទាហរណ៍ខ្លះៗ នៅពេលដែលការសម្រុះសម្រួល អាចផ្តល់សិទ្ធិអំណាចដល់ស្ត្រីរងគ្រោះគឺ៖

- ❖ នៅពេលដំណើរការត្រូវបានធ្វើឡើងនៅកន្លែងដែលមានសុវត្ថិភាព
- ❖ នៅពេលស្ត្រីមានអំណាចក្នុងការចូលរួមដោយបើកចំហ និងស្មើភាព
- ❖ នៅពេលស្ត្រីមានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងឈានទៅរកកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្ត និងមិនមានការបង្ខិតបង្ខំ

ជាការពិតគឺថា ទោះបីជាមានផលវិជ្ជមាននិងអវិជ្ជមាន នៃការសម្រុះសម្រួលយ៉ាងដូចនេះក៏ដោយ ក៏ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារភាគច្រើន នៅតែបន្តធ្វើការជ្រើសរើសការសម្រុះសម្រួល ដោយសារភាពស្មុគស្មាញនៃកត្តាសង្គម វប្បធម៌ ឬ សេដ្ឋកិច្ចដូចបានរៀបរាប់ខាងដើម។

## ៤.៣ សមាសភាពអ្នកសម្រុះសម្រួល៖

ដើម្បីធានាឱ្យបាននូវគោលការណ៍សមភាព សមធម៌ និង គោលការណ៍ផ្តោតលើសិទ្ធិស្ត្រីរងគ្រោះជាចម្បង សមាសភាពអ្នកសម្រុះសម្រួលនៅថ្នាក់រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ រួមទាំងអ្នកសម្រុះសម្រួលឯករាជ្យ ជាពិសេសក្នុងដំណើរការអនុវត្តគ្រប់ដំណាក់កាលនៃការសម្រុះសម្រួលទាំងអស់ ចាំបាច់ត្រូវមានសមាសភាពស្ត្រីជាអ្នកសម្រុះសម្រួល(សន្ធានការី)។ ទាំងនេះក៏ស្របទៅនឹងស្មារតីនៃគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ក៏ដូចជា អនុក្រឹត្យលេខ១៨២, ១៨៣, ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពី មុខងារនិងរចនាសម្ព័ន្ធរដ្ឋបាល ក្រុង-ស្រុក-ខណ្ឌ នៃរាជធានីខេត្តផងដែរ ដែលកំណត់ពីអាទិភាពដល់ស្ត្រីសម្រាប់មុខតំណែង និងបុគ្គលិកភាពក្នុងការិយាល័យទាំងនេះ។ ក្នុងបរិបទនៃយន្តការដោះស្រាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គោលការណ៍ណែនាំនេះ លើកទឹកចិត្តឱ្យមានការចូលរួមសហសម្រុះសម្រួលពីមន្ត្រីជំនាញទទួលបន្ទុកកិច្ចការនារីនៃការិយាល័យសង្គមកិច្ច និង

សុខុមាលភាពសង្គម នៅថ្នាក់ក្រុង-ស្រុក-ខណ្ឌ ឬ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ នៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារនៅថ្នាក់ឃុំ-សង្កាត់។

## ៤.៤ តួនាទីរបស់អ្នកសម្រុះសម្រួល

អ្នកសម្រុះសម្រួល ដើរតួជាអ្នកសម្របសម្រួលមិនមែនជា "អាជ្ញាកណ្ដាល" កាត់ក្ដីនោះទេ ដើម្បីជួយសម្រួលភាគីទាំងសងខាងក្នុងការដោះស្រាយវិវាទរបស់ពួកគេឱ្យសះជា។ អ្នកសម្រុះសម្រួល គ្រាន់តែធ្វើការ សម្របសម្រួល ដំណើរការសម្រុះសម្រួលប៉ុណ្ណោះ ដោយទទួលស្គាល់ថាអ្នកដែលត្រូវធ្វើសេចក្ដីសម្រេចចិត្តពិតប្រាកដ គឺជាភាគីវិវាទខ្លួនឯង។ "សម្របសម្រួល" មានន័យថា អ្នកសម្រុះសម្រួលមានវត្តមាននៅទីនោះ ដើម្បីជួយភាគីក្នុងការប្រាស្រ័យទាក់ទងគ្នា និងពិភាក្សាពីការបង្កើតជម្រើសនានា ដើម្បីឈានទៅរកដំណោះស្រាយដែលអាចទទួល យកបានពីភាគីទាំងសងខាង។ ការសម្រុះសម្រួលដែលជោគជ័យមិនចាំបាច់ ទាល់តែឈានដល់កិច្ចព្រមព្រៀងគ្នានោះទេ។ ក្នុងករណីខ្លះ វាអាចកើតឡើងដែលថា អ្នកសម្រុះសម្រួលជួយភាគីឱ្យពិចារណាលើជម្រើសទាំងអស់ដែលពួកគេបង្កើតឡើង ហើយនៅចុងបញ្ចប់ ខាងភាគីបុរសប្រហែលជាចង់ផ្សះផ្សា ហើយភាគីស្ត្រីចង់លែងលះ។ នេះមិនមែនជាការសម្រុះសម្រួលដែលបរាជ័យនោះទេ។ ដំណើរការនេះបានជួយឱ្យភាគីទាំងពីរបញ្ជាក់ពីអ្វីដែលពួកគេចង់បាន។

**អ្នកសម្រុះសម្រួលគួរចៀសវាង ៖**

- ❖ ការផ្ដល់ដំបូន្មានដែលមានផ្ទត់គំនិតយេនឌ័រ អវិជ្ជមាន ដែលគួរជំនួសវិញដោយការសម្របសម្រួលការពិភាក្សា។
- ❖ ការបញ្ចេញមតិលើវិវាទ។
- ❖ រំពឹងថាភាគីនានានឹងស្របតាមទស្សនៈ ឬយោបល់របស់អ្នកសម្រុះសម្រួល។
- ❖ ចេញបញ្ជា ឬដាក់ដំណោះស្រាយ និង។
- ❖ អាក់អន់ចិត្តនៅពេលដំណោះស្រាយទាំងនោះមិនត្រូវបានអនុវត្តតាម។

អ្នកសម្រុះសម្រួល មិនត្រូវ ផ្ដល់យោបល់ វាយតម្លៃវិវាទ បង្គាប់ដោយផ្ទាល់ ឬ ដាក់ចេញនូវដំណោះស្រាយ ឬ គោលបំណងផ្ទាល់ខ្លួនមកលើភាគីឡើយ ដែលប្រការនេះមិនស្របទៅនឹងភាពមិនលម្អៀង និងគោលបំណងនៃការសម្រុះសម្រួលហើយអាចបណ្ដាលឱ្យមានការរំលោភបំពានសិទ្ធិថែមទៀត។

ជាទូទៅ អ្នកសម្រុះសម្រួល គឺជាអាជ្ញាធរដែលមានមុខងារ ឬ ជាសមាជិកសហគមន៍ ដែលទទួលបានការគោរព ឬ ជាអ្នកមានឥទ្ធិពលនៅក្នុងសហគមន៍។ អំណាច ឬ ឥទ្ធិពលនេះ អាចធ្វើឱ្យភាគីវិវាទមានការស្ទាក់ស្ទើរក្នុងការបញ្ចេញមតិ ឬ ធ្វើការសម្រេចចិត្តណាមួយ ដែលខ្លួនគិតថាអាចធ្វើឱ្យអ្នកសម្រុះសម្រួលមានការអាក់អន់ចិត្ត។ ដូច្នេះ អ្នកសម្រុះសម្រួលត្រូវតែធានាថា អំណាច ឬ ឥទ្ធិពលរបស់ខ្លួននឹងមិនរឹតត្បិតសិទ្ធិសេរីភាពរបស់ភាគីក្នុងការបញ្ចេញមតិ និងបង្កើតជម្រើស ជាពិសេស នឹងមិនរំលោភលើសិទ្ធិរបស់ភាគីក្នុងការធ្វើសេចក្ដីសម្រេចចិត្តដោយខ្លួនឯង។

# ៥ គោលការណ៍សម្រុះសម្រួលក្នុងបរិបទនេះ

អ្នកសម្រុះសម្រួលត្រូវគោរពតាមគោលការណ៍ដូចខាងក្រោមដើម្បីធានាថា ដំណើរការសម្រុះសម្រួលបានគិតគូរពិចារណាពីភាពជាក់ស្តែងនៃអំពើហិង្សាលើស្ត្រី រួមទាំងភាពដែលអាចទៅរួចដែលថាករណីអ្វីក៏ដោយ ដែលយកមកសម្រុះសម្រួលអាចមានពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី។ អ្នកសម្រុះសម្រួលចាំបាច់ត្រូវគោរព ការពារ លើកកម្ពស់ និងបំពេញសិទ្ធិរបស់ភាគីវិវាទទាំងអស់ ដោយផ្តោតសំខាន់ទៅលើសិទ្ធិរបស់ស្ត្រីរងគ្រោះ។ អ្នកសម្រុះសម្រួលត្រូវធានាថា ទាំងដំណើរការសម្រុះសម្រួល និងលទ្ធផលនៃការសម្រុះសម្រួល គឺស្របនឹងវិសាលភាព ដែនកំណត់ និងគោលការណ៍ ដែលមានចែងនៅក្នុងគោលការណ៍ណែនាំនេះ។

**សង្ខេបគោលការណ៍នៃដំណើរការសម្រុះសម្រួលក្នុងបរិបទអំពើហិង្សាលើស្ត្រី**

១. គោលការណ៍នីត្យានុកូលភាព
២. ភាពសមស្រប
៣. ការគោរពសិទ្ធិស្ត្រីរងគ្រោះ
៤. ការយល់ព្រមនិងចូលរួមដោយស្ម័គ្រចិត្ត
៥. ការចូលរួមដោយស្មើភាពនិងប្រកបដោយអត្ថន័យ
៦. គោលការណ៍ស្វ័យភាពនិងសិទ្ធិស្វ័យសម្រេច
៧. សុវត្ថិភាពនិងការការពារ
៨. ឯករាជ្យភាពនិងអព្យាក្រឹតភាព
៩. ការរក្សាការសម្ងាត់
១០.សមត្ថភាពអ្នកសម្រុះសម្រួល

## ៥.១ ការសម្រុះសម្រួលដែលអាចធ្វើទៅបាន ចាំបាច់ត្រូវស្របនឹងគោលការណ៍ នីត្យានុកូលភាពនៃច្បាប់ក្នុងប្រទេសកម្ពុជា

អ្នកសម្រុះសម្រួលត្រូវធានាថា គ្រប់ដំណាក់កាលនៃការសម្រុះសម្រួល ត្រូវតែស្ថិតនៅក្រោមច្បាប់នៃប្រទេសកម្ពុជា ដូចដែលបានពិភាក្សាក្នុង ចំណុចទី៣ ខាងលើ។ ការកំណត់ពីកត្តានីត្យានុកូលភាពនៃការសម្រុះសម្រួលគ្រប់វិវាទចាំបាច់ត្រូវធ្វើឡើងតាមរយៈនីតិវិធីត្រួតពិនិត្យបឋមលើករណីឱ្យបានត្រឹមត្រូវ នៅគ្រប់ដំណាក់កាលនៃការសម្រុះសម្រួល ដោយមិនប្រើតាម "អារម្មណ៍ ឬ ធ្វើការប៉ាន់ស្មាន" នោះទេ។ សម្រាប់ដំណើរការលម្អិត សូមមើលចំណុចទី៦ ស្តីពីគោលការណ៍ណែនាំអំពី

នីតិវិធីសម្រុះសម្រួល។ សូមចងចាំថា ភាគីដែលកំពុងស្វែងរកការសម្រុះសម្រួលត្រូវតែមានអំណាចស្មើគ្នាដើម្បីអាចចរចា និងប្រាស្រ័យទាក់ទងគ្នាដោយស្មើភាពនិងដោយមិនមានការភ័យខ្លាច។

## ៥.២ ការសម្រុះសម្រួលចាំបាច់ត្រូវមានភាពសមស្រប

អ្នកសម្រុះសម្រួលចាំបាច់ត្រូវកំណត់ថា តើការសម្រុះសម្រួលក្នុងករណីនេះមានលក្ខណៈសមស្របដែរឬទេ តាមរយៈការត្រួតពិនិត្យបឋមលើករណីឱ្យបានត្រឹមត្រូវទៅលើចរិតលក្ខណៈនៃករណី និងកាលៈទេសៈដែលពាក់ព័ន្ធ។ ខាងក្រោមនេះជាសំណួរខ្លះៗដើម្បីជួយកំណត់ថា តើការសម្រុះសម្រួលមានលក្ខណៈសមស្របដែរឬទេ៖

*១. តើការសម្រុះសម្រួលនេះអាចឆ្លើយតបទៅនឹងគោលបំណងរបស់ស្ត្រីរងគ្រោះដែរឬទេ?*

ដូចបានបញ្ជាក់ខាងលើ ការសម្រុះសម្រួលករណីវិវាទក្នុងបរិបទនេះ ចាំបាច់ត្រូវតែផ្តោតសំខាន់ទៅលើសិទ្ធិមនុស្ស និងត្រូវបានផ្តួចផ្តើមដោយគោរពតាមឆន្ទៈរបស់ស្ត្រីរងគ្រោះផងដែរ។ លទ្ធផលនៃការសម្រុះសម្រួលមិនអាចនាំទៅរកការដាក់ទោសទណ្ឌទៅកាន់ភាគីនោះទេ។ ដូចនេះ ប្រសិនបើស្ត្រីរងគ្រោះចង់ឱ្យជនមុខសញ្ញា ត្រូវជាប់ទោសដាក់ពន្ធនាគារដោយអនុលោមទៅតាមច្បាប់ជាធរមាន ការសម្រុះសម្រួលករណីបែបនេះ មិនមានលក្ខណៈស្របច្បាប់និងសមស្របនោះទេ ហើយដំណើរការសម្រុះសម្រួលក៏មិនអាចអនុវត្តបានឡើយ។ ទោះបីនៅក្នុងអំឡុងពេលអនុវត្តដំណើរការសម្រុះសម្រួលក៏ដោយ ប្រសិនបើស្ត្រីរងគ្រោះបង្ហាញថា ខ្លួនចង់បញ្ចប់ដំណើរការនេះ នោះដំណើរការសម្រុះសម្រួលនឹងត្រូវបញ្ចប់។ នៅពេលដែលអ្នកសម្រុះសម្រួលបានត្រួតពិនិត្យបន្តឃើញមានកត្តារាំងស្ទះចំពោះការសម្រុះសម្រួល ដូចជា អតុល្យភាពនៃអំណាច ឬ មានករណីអំពើហិង្សាកើតមានឡើង នោះដំណើរការសម្រុះសម្រួលគួរតែត្រូវបញ្ចប់។ អ្នកសម្រុះសម្រួលត្រូវពន្យល់ប្រាប់ទៅភាគីអំពីមូលហេតុដែលធ្វើអោយការសម្រុះសម្រួលមិនអាចដំណើរការទៅមុខទៀតបាន ហើយភាគីត្រូវបានណែនាំនិងបញ្ជូនបន្តទៅកាន់តុលាការ និង/ឬ យន្តការនិងសេវាគាំទ្រពាក់ព័ន្ធនានា។

*២. តើការសម្រុះសម្រួលអាចបង្ការទប់ស្កាត់អំពើហិង្សា និងការពារស្ត្រីរងគ្រោះឬទេ?*

អ្នកសម្រុះសម្រួល ចាំបាច់ត្រូវផ្តល់អាទិភាពដល់សិទ្ធិរបស់ស្ត្រីរងគ្រោះជាសំខាន់ ជាពិសេសគឺសិទ្ធិក្នុងការទទួលបានយុត្តិធម៌និងសុវត្ថិភាពលើរូបរាងកាយ។ ប្រសិនបើ អ្នកសម្រុះសម្រួល មិនអាចធានាបាននូវដំណើរការសម្រុះសម្រួលមួយដែលរក្សានូវសុវត្ថិភាពឱ្យភាគីគេចផុតពីការគំរាមកំហែង ឬ អំពើហិង្សា

បានទេ នោះមានន័យថា ការសម្រុះសម្រួលនេះគឺមិនអាចធ្វើឡើងបានឡើយ ហើយករណីនេះត្រូវបញ្ជូនបន្តទៅតុលាការ។ បន្ថែមពីនេះ គោលបំណងនៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ គឺបង្ការទប់ស្កាត់អំពើហិង្សា និងការពារជនរងគ្រោះ និងលើកកម្ពស់វប្បធម៌អហិង្សានៅក្នុងប្រទេសកម្ពុជា។ ក្នុងករណីដែលលទ្ធផលនៃការសម្រុះសម្រួលមិនបម្រើស្មារតី និងគោលបំណងនៃច្បាប់នេះទេ នោះការសម្រុះសម្រួលនេះមិនគួរត្រូវបានអនុវត្តទាល់តែសោះ ឬ គួរតែត្រូវបានបញ្ចប់។

***៣. តើការសម្រុះសម្រួលករណីនេះនឹងផ្តល់ផលប្រយោជន៍ជាសាធារណៈ ដោយផ្ញើសារទៅកាន់សាធារណៈថា អំពើហិង្សាលើស្ត្រីគឺជាបទឧក្រិដ្ឋដែរឬទេ?***

អ្នកសម្រុះសម្រួលត្រូវគិតគូរពីប្រយោជន៍សាធារណៈ មុននឹងអនុវត្តដំណើរការសម្រុះសម្រួលវិវាទ។ វាជាការសំខាន់ដែលត្រូវចងចាំថា ការកាត់ទោសបទឧក្រិដ្ឋនៃអំពើហិង្សាលើស្ត្រី គឺជាប្រយោជន៍សាធារណៈ។ ប្រយោជន៍សាធារណៈ នេះគឺការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព ការបំបែកវប្បធម៌នៃភាពស្ងៀមស្ងាត់ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ និងការផ្ញើសារយ៉ាងសំខាន់ទៅកាន់សហគមន៍ថា អំពើហិង្សាលើស្ត្រីគឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ដែលមិនមែនត្រឹមតែរំលោភសិទ្ធិស្ត្រីរងគ្រោះនោះទេ វាថែមទាំងរំលោភលើគុណតម្លៃសាធារណៈនៃការគោរពចំពោះមនុស្ស សិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស សមភាពយេនឌ័រ និងសន្តិសុខរបស់មនុស្ស។

អ្នកសម្រុះសម្រួល គួរតែចៀសវាងធ្វើការសម្រុះសម្រួលនៅពេលដែលការត្រួតពិនិត្យបឋមលើករណីត្រូវបានរកឃើញថាមិនមានភាពសមស្រប ទោះបីស្ត្រីរងគ្រោះទទូចស្នើសុំឱ្យធ្វើការសម្រុះសម្រួលក៏ដោយ។ អ្នកសម្រុះសម្រួលត្រូវតែបញ្ជូនករណីទៅរកយន្តការសមស្របនិងសេវាពាក់ព័ន្ធនានា ក្នុងករណីដែលមិនអាចសម្រុះសម្រួលបាន។

## ៥.៣. ដំណើរការ និងលទ្ធផល នៃការសម្រុះសម្រួលត្រូវគោរពសិទ្ធិស្ត្រីរងគ្រោះ

សិទ្ធិជាមូលដ្ឋានដែលដំណើរការសម្រុះសម្រួលត្រូវតែគោរពនោះគឺ សិទ្ធិរបស់ស្ត្រីរងគ្រោះក្នុងការទទួលបានដំណោះស្រាយដែលមានប្រសិទ្ធភាព។ លើសពីនេះ ដំណើរការ និងលទ្ធផលនៃការសម្រុះសម្រួល ត្រូវតែគោរព ការពារ លើកកម្ពស់ និង បំពេញសិទ្ធិមនុស្សទាំងអស់ រួមទាំងសិទ្ធិទទួលបានភាពស្មើគ្នា និងការមិនរើសអើង។ ក្នុងករណីដែលដំណើរការ និងលទ្ធផល នៃការសម្រុះសម្រួលមិនគោរពសិទ្ធិមនុស្ស នោះដំណើរការសម្រុះសម្រួលនេះមិនមានលក្ខណៈសមស្របនោះទេ។ ខាងក្រោមនេះជាសិទ្ធិមួយចំនួនរបស់ស្ត្រីរងគ្រោះ៖

១. សិទ្ធិមានសេរីភាព រួចផុតពីការរំលោភបំពាន និងអំពើហិង្សាគ្រប់ទម្រង់ទាំងអស់។

២. សិទ្ធិក្នុងការទទួលបានដីកាការពារ ឬ សេចក្តីសម្រេចរដ្ឋបាល ដើម្បីធានានូវសុខសុវត្ថិភាពរបស់ស្ត្រីនៅគ្រប់ដំណាក់កាលទាំងអស់។

៣. សិទ្ធិទទួលបានភាពស្មើគ្នា និងការមិនរើសអើង។

៤. សិទ្ធិក្នុងការដាក់ពាក្យបណ្តឹង ទៅមន្ត្រីនគរបាល ឬ អាជ្ញាធរមានសមត្ថកិច្ចដែលសមស្រប ដើម្បីកាត់ទោសជនមុខសញ្ញាស្របតាមច្បាប់ក្នុងប្រព័ន្ធតុលាការ ជំនួសឱ្យការជ្រើសរើសយកការដោះស្រាយក្រៅប្រព័ន្ធតុលាការ។

៥. សិទ្ធិក្នុងការសម្រេចចិត្តដោយសេរី និងស្ម័គ្រចិត្ត ថាតើត្រូវចូលរួមដំណើរការសម្រុះសម្រួលដែរឬទេ បន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយស្តីពីជម្រើសនានា និងផលវិបាកនៃជម្រើសទាំងនោះ។

៦. សិទ្ធិផ្តាច់មុខ ក្នុងការផ្តួចផ្តើមដំណើរការសម្រុះសម្រួល និងកំណត់គោលបំណងរបស់ខ្លួននៅក្នុងដំណើរការសម្រុះសម្រួលនោះ។

៧. សិទ្ធិមានវត្តមាន និងចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការសម្រុះសម្រួល និងសិទ្ធិក្នុងការដកខ្លួនចេញពីការសម្រុះសម្រួលនៅពេលណាមួយ ឬ ផ្លាស់ប្តូរអ្នកសម្រុះសម្រួល ប្រសិនបើនាងមិនមានជំនឿទុកចិត្ត និងជឿជាក់លើបុគ្គលសម្រុះសម្រួលនោះ។

៨. សិទ្ធិទទួលបានទីកន្លែងសម្រុះសម្រួលដែលអនុញ្ញាតឱ្យមានភាពឯកជន និងភាពងាយស្រួល រួមទាំងសម្រាប់ជនមានពិការភាពផងដែរ។

៩. សិទ្ធិក្នុងការគ្រប់គ្រងថា នរណាគួរមានវត្តមាននៅក្នុងដំណើរការសម្រុះសម្រួល និងសិទ្ធិក្នុងការនាំអ្នកអម ឬ អ្នកគាំទ្រមកជាមួយ។

១០. សិទ្ធិក្នុងការបង្ហាញពីអារម្មណ៍និងទស្សនៈយល់ឃើញ ដោយសេរីអំពីការរំលោភបំពាននិងពន្យល់ពីផលប៉ះពាល់ដែលបង្កឡើងដោយការរំលោភបំពាននោះ ដោយមិនមានការវិនិច្ឆ័យបែបផ្នត់គំនិតយេនឌ័រនោះទេ។

១១. សិទ្ធិទទួលបានការការពារ និងចៀសផុតពីការគំរាមកំហែង ការបំភិតបំភ័យ ឥទ្ធិពលហួសហេតុ ឬ សម្ពាធ ការបៀតបៀន ឬ អំពើហិង្សាគ្រប់ទម្រង់ទាំងអស់ ក្នុងអំឡុងពេល ឬ ក្រោយពេលបញ្ចប់ដំណើរការសម្រុះសម្រួល។

១២. សិទ្ធិក្នុងការទាមទារសំណង និងសិទ្ធិទាមទារឱ្យជនមុខសញ្ញាឈប់ប្រព្រឹត្តអំពើរំលោភបំពានបន្តទៀត។

១៣. សិទ្ធិទាមទារឱ្យជនមុខសញ្ញា ទទួលស្គាល់ការរំលោភបំពានជាលាយលក្ខណ៍អក្សរជាផ្នែកមួយនៃកិច្ចព្រមព្រៀង។

១៤. សិទ្ធិក្នុងការទាមទារឱ្យជនមុខសញ្ញាចាត់វិធានការវិជ្ជមាន ដើម្បីផ្លាស់ប្តូរអាកប្បកិរិយារំលោភបំពាន ដូចជាតាមរយៈការទទួលការប្រឹក្សាយោបល់ ឬ ការធ្វើអន្តរាគមន៍ផ្នែកចិត្តសាស្ត្រផ្សេងទៀត។

១៥. សិទ្ធិក្នុងការទទួលបានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ នៅចុងបញ្ចប់នៃការសម្រុះសម្រួល ដែលឆ្លុះបញ្ចាំងដោយស្មោះត្រង់នូវចំណុចដែលបានព្រមព្រៀងគ្នា ប្រសិនបើការសម្រុះសម្រួលអាចឈានដល់កិច្ចព្រមព្រៀងមួយ។

១៦. សិទ្ធិទាមទារឱ្យមានការឃ្លាំមើលពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាន ដោយឱ្យជនមុខសញ្ញាគោរពតាមកិច្ចព្រមព្រៀង។

១៧. សិទ្ធិមិនតម្រូវឱ្យមានកិច្ចព្រមព្រៀងជាមួយជនមុខសញ្ញា។

## ៥.៤. ស្ត្រីរងគ្រោះបានយល់ព្រម និងចូលរួមដោយការស្ម័គ្រចិត្ត

ដំណើរការសម្រុះសម្រួល អាចប្រព្រឹត្តទៅបានលុះត្រាតែស្ត្រីរងគ្រោះស្នើសុំតែប៉ុណ្ណោះ។ អ្នកសម្រុះសម្រួលអាចបន្តការសម្រុះសម្រួលបាន លុះត្រាតែស្ត្រីរងគ្រោះបានជ្រើសរើសការសម្រុះសម្រួលដោយសេរីបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយអំពីសិទ្ធិ និងជម្រើសរបស់ស្ត្រីរងគ្រោះ និងផលវិបាកដែលអាចកើតមាន ចេញពីការសម្រុះសម្រួល។ ការណ៍នេះទាមទារឱ្យអ្នកសម្រុះសម្រួលជួបប្រជុំដាច់ដោយឡែកជាមួយស្ត្រីរងគ្រោះ ដោយប្រើនីតិវិធីត្រួតពិនិត្យបឋមលើករណី និងពន្យល់អំពីសិទ្ធិរបស់គាត់ដើម្បីកំណត់គោលបំណងរបស់ស្ត្រីរងគ្រោះ ដោយមិនមានការបំភិតបំភ័យ និងមិនមានវត្តមានជនមុខសញ្ញា ឬ អ្នកដទៃដែលស្ត្រីរងគ្រោះមិនយល់ព្រម។

នៅពេលដែលស្ត្រីរងគ្រោះទទួលសម្ពាធពីអ្នកដទៃ ដូចជា សមាជិកគ្រួសារស្ត្រីរងគ្រោះ ឬ ជនមុខសញ្ញា ឱ្យជ្រើសរើសការសម្រុះសម្រួល នោះគឺជាការរំលោភបំពានសិទ្ធិរបស់ស្ត្រីរងគ្រោះ។ ចំពោះហេតុផលនេះ មន្ត្រីនគរបាល ឬ អាជ្ញាធរ មូលដ្ឋានណាមួយ មិនត្រូវកោះហៅស្ត្រីរងគ្រោះមក

ចូលធ្វើការសម្រុះសម្រួល ដោយគ្មានការស្នើសុំជាមុនពីស្ត្រីរងគ្រោះនោះឡើយ។ គ្រប់ដំណាក់កាលនៃដំណើរការសម្រុះសម្រួល ត្រូវតែគោរពសិទ្ធិក្នុងការចូលរួមដោយស្ម័គ្រចិត្តរបស់ស្ត្រីរងគ្រោះ។ ស្ត្រីរងគ្រោះអាចនឹងបញ្ចប់ដំណើរការសម្រុះសម្រួលនេះគ្រប់ពេល ឬ នៅពេលនាងយល់ថា វាមិនឆ្លើយតបនឹងតម្រូវការរបស់នាង។

*ការចូលរួមដោយស្ម័គ្រចិត្តក្នុងការសម្រុះសម្រួល គឺជាកត្តាគន្លឹះក្នុងការកំណត់ភាពជោគជ័យនៃដំណើរការសម្រុះសម្រួល។*

## ៥.៥. ស្ត្រីរងគ្រោះត្រូវតែមានការចូលរួមដោយស្មើភាព និងប្រកបដោយអត្ថន័យ

ភាគីស្ត្រីគួរត្រូវបានផ្តល់ជម្រើសឱ្យមានអ្នកអម ឬ អ្នកគាំទ្រ នៅក្នុងដំណើរការសម្រុះសម្រួល។ ដើម្បីឱ្យភាគីស្ត្រីអាចចូលរួមស្មើភាពគ្នា និងមានប្រសិទ្ធភាពក្នុងដំណើរការសម្រុះសម្រួល វាចាំបាច់ដែលថា៖

(១) ស្ត្រីរងគ្រោះ ត្រូវទទួលបានការណែនាំអំពីសិទ្ធិ និងជម្រើសរបស់នាង។ នាងត្រូវតែទទួលបានព័ត៌មានពេញលេញថា នាងមានសិទ្ធិក្នុងការជ្រើសរើសដោយសេរីក្នុងចំណោមជម្រើសរបស់នាង ដោយគ្មានសម្ពាធ ការបំភិតបំភ័យ ឬ ការបង្ខិតបង្ខំ ពីនរណាម្នាក់ឡើយ។ នាងក៏ត្រូវបានណែនាំផងដែរថា នាងអាចដកខ្លួនចេញពីដំណើរការសម្រុះសម្រួលគ្រប់ពេល ដោយមិនមានផលវិបាកជះមកលើនាងវិញឡើយ។ ក្នុងករណីដែលអាចធ្វើទៅបាន នាងអាចត្រូវបានបញ្ជូនទៅមេធាវីដែលអាចពន្យល់អំពីសិទ្ធិ និងជម្រើសរបស់នាងយ៉ាងហ្មត់ចត់។

(២) ស្ត្រីរងគ្រោះ ត្រូវបានផ្តល់ការប្រឹក្សាយោបល់មុនការប្រព្រឹត្តឡើងនៃដំណើរការសម្រុះសម្រួល ហើយបើចាំបាច់ បញ្ជូនស្ត្រីទៅរកសេវាវេជ្ជសាស្ត្រ ជម្រកសុវត្ថិភាព ឬ សេវាការពារនិងជំនួយសេដ្ឋកិច្ច។

(៣) អ្នកសម្រុះសម្រួលត្រូវអនុវត្តតាម គោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រីនិងក្មេងស្រីដែលជាជនរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបង្កើតឡើងដោយក្រសួងកិច្ចការនារី ក្នុងការបញ្ជូនស្ត្រីរងគ្រោះទៅរកសេវាសមស្រប។[២]

២ គោលការណ៍ណែនាំនេះ គ្របដណ្តប់អ្នកផ្តល់សេវាទាំងអស់ ដោយបានកំណត់ថាជា អ្នកផ្តល់សេវាទាំងអស់ទាំងស្ថាប័នរដ្ឋ និងមិនមែនរដ្ឋ ក្រុមអ្នកស្ម័គ្រចិត្ត និងអ្នកពាក់ព័ន្ធដទៃទៀតដែលផ្តល់សេវានិងគាំទ្រដល់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ។ អ្នកសម្រុះសម្រួលត្រូវបានរួមបញ្ចូលថាជាអ្នកផ្តល់សេវាដែរ។

(៤)	ស្ត្រីរងគ្រោះត្រូវទទួលបានដំណឹង ថានាងមានសិទ្ធិក្នុងការជ្រើសរើស និងនាំអ្នកអម ឬអ្នកគាំទ្រ ចូលក្នុងដំណើរការសម្រុះសម្រួលបាន។

(៥)	ស្ត្រីរងគ្រោះបានដឹងច្បាស់ថា នាងមានសិទ្ធិក្នុងការបញ្ចេញទស្សនៈ និងកង្វល់នានា ហើយថាទស្សនៈបំណងប្រាថ្នា និងការសម្រេចចិត្តរបស់នាងនឹងត្រូវបានគោរព។

(៦)	ស្ត្រីរងគ្រោះបានដឹងច្បាស់ថា នាងមានសិទ្ធិបញ្ចេញនូវបញ្ហាផ្លូវចិត្ត និងអារម្មណ៍ពីអំពើហិង្សាដែលនាងបានជួបប្រទះ និងកំហឹងរបស់នាងចំពោះជនល្មើស។ ការអនុញ្ញាតឱ្យនាងបង្ហាញនូវបញ្ហាផ្លូវចិត្ត និងអារម្មណ៍របស់នាង រួមទាំងកំហឹងរបស់នាង អាចជាផ្នែកមួយនៃវិធីសាស្ត្របន្ធូរអារម្មណ៍តានតឹងរបស់ស្ត្រីរងគ្រោះ ដែលអាចរួមចំណែកដល់ដំណើរការជាសះស្បើយរបស់នាង។

(៧)	អ្នកសម្រុះសម្រួលត្រូវចងចាំជានិច្ចថា ស្ត្រីរងគ្រោះស្ថិតក្នុងស្ថានភាពងាយរងគ្រោះនិងចាញ់ប្រៀបជនមុខសញ្ញា ដែលបណ្តាលមកពីការរំលោភបំពាន និងទម្រង់ផ្សេងៗនៃការរើសអើងក្នុងសង្គមចំពោះស្ត្រីរងគ្រោះ។ វាអាចទៅរួចដែលថា ស្ត្រីរងគ្រោះអាចខំមាត់សង្កត់ចិត្តទទួលយកលក្ខខណ្ឌដោះស្រាយផ្សេងៗ ដែលមិនសូវអំណោយផលដល់នាងដោយសារតែនាងមានតម្រូវការហិរញ្ញវត្ថុ ការខ្វល់ខ្វាយពីកូនៗ ឬ កង្វះខាតធនធាន ដើម្បីបន្តដំណើរការក្តីនៅតុលាការ។

(៨)	អ្នកសម្រុះសម្រួលត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ស្ត្រីរងគ្រោះ ក្នុងការគិតត្រិះរិះពីជម្រើសរបស់នាង ឬ សំណើណាមួយដែលត្រូវបានស្នើឡើងក្នុងដំណើរការសម្រុះសម្រួលឱ្យបានល្អិតល្អន់។ នាងអាចពិគ្រោះយោបល់ជាមួយមនុស្សដែលនាងទុកចិត្ត រួមទាំងមេធាវីផងដែរ ស្តីពីជម្រើសរបស់នាង។ នាងមិនគួរប្រញាប់ប្រញាល់ក្នុងការសម្រេចចិត្តទេ។ អ្នកសម្រុះសម្រួលគួររៀបចំការប្រជុំសម្រុះសម្រួលឱ្យលើសពីម្តង ដើម្បីឱ្យភាគីមានពេលវេលាគ្រប់គ្រាន់ក្នុងការពិចារណា និងធ្វើសេចក្តីសម្រេចចិត្ត លើជម្រើសដោះស្រាយដែលបានស្នើឡើង។

## ៥.៦. គោលការណ៍ស្វ័យភាព និងសិទ្ធិស្វ័យសម្រេច

ចំណុចពិសេសមួយនៃការសម្រុះសម្រួលនោះគឺ ដំណើរការនេះអាចផ្តល់នូវឱកាសសម្រាប់ភាគី ក្នុងការស្វែងរកដំណោះស្រាយដែលប្រកបដោយភាពច្នៃប្រឌិត និងសមស្របទៅនឹងតម្រូវការ និងការព្រួយបារម្ភរបស់ស្ត្រីរងគ្រោះដែលទាំងនេះប្រហែលជាមិនអាចធ្វើបានឡើយតាមរយៈប្រព័ន្ធតុលាការ។ ស្ត្រីរងគ្រោះត្រូវតែមានលទ្ធភាពទទួលបានព័ត៌មានពេញលេញអំពីលក្ខណៈនៃដំណើរការសម្រុះសម្រួល សិទ្ធិរបស់ពួកគេ និងជម្រើសដែលមានសម្រាប់ពួកគេ។ ពួកគេត្រូវបានផ្តល់ឱកាសឱ្យពិចារណាលើជម្រើសទាំងអស់ និងពិគ្រោះយោបល់ជាមួយអ្នកជំនាញ និងអ្នកគាំទ្រ ដើម្បីជួយពួកគេធ្វើការសម្រេចចិត្តមួយដែលមានព័ត៌មានគ្រប់ជ្រុងជ្រោយ។

### ស្ត្រីមានពិការភាពនិងស្ត្រីងាយរងគ្រោះផ្សេងៗ

សម្រាប់អ្នកដែលមានបញ្ហាស្តាប់ ឬនិយាយ ឬមានសមត្ថភាពខ្សោយខាងស្មារតី ឬផ្លូវចិត្ត អ្នកសម្រុះសម្រួលត្រូវចាត់វិធានការ ដើម្បីធានាថាបុគ្គលនោះមានសមត្ថភាព ផ្តល់ការព្រមព្រៀងដោយស្ម័គ្រចិត្ត និងដោយមានជំនួយពីអ្នកបកប្រែភាសា សញ្ញាជំនួយពីអ្នកជំនាញ ឬ អ្នកគាំទ្រពីអង្គការដែលធ្វើការជាមួយអ្នកមានពិការភាព។ ទោះបីជាមានវត្តមានអ្នកគាំទ្រដើម្បីជួយជនមានពិការភាពនៅក្នុងការសម្រុះសម្រួលក៏ដោយ អ្នកសម្រុះសម្រួលត្រូវធានាថា ភាគីមានពិការភាពនៅតែជាអ្នកសម្រេចចិត្តក្នុងកិច្ចព្រមព្រៀងដោយខ្លួនឯង។ ចំពោះក្រុមស្ត្រីងាយរងគ្រោះផ្សេងទៀត អ្នកសម្រុះសម្រួលត្រូវចាត់វិធានការដើម្បីធានាឱ្យបាននូវការចូលរួមពេញលេញមានអត្ថន័យ និងការទទួលបានការគាំទ្រទៅតាមតម្រូវការជាក់ស្តែង ដូចជា ការបកប្រែភាសា ជាដើម។

## ៥.៧. គោលការណ៍សុវត្ថិភាព និងការការពារ

អ្នកសម្រុះសម្រួល ត្រូវចងចាំថាស្ត្រីរងគ្រោះ ទំនងជាអាចប្រឈមនឹងហានិភ័យ នៃអំពើហិង្សា ឬការគំរាមកំហែង នៃអំពើហិង្សាបន្ថែមទៀត ក្នុងអំឡុងពេល និងក្រោយពេលសម្រុះសម្រួលចប់។ ស្ត្រីអាចត្រូវបានដៃគូស្និទ្ធស្នាល ឬ ឪពុកម្តាយបងប្អូន ពូមីង មិត្តភក្តិ ឬ អ្នកជិតខាងបង្ខំឱ្យទ្រាំនឹងអំពើហិង្សា ដើម្បីការពារមុខមាត់គ្រួសារ ឬ ដើម្បីចៀសវាងការអាម៉ាសមុខដែលកើតចេញពីការលះលែង ឬ បណ្តឹងក្តីក្តាំនៅតុលាការ។

ក្នុងកាលៈទេសៈនេះ ស្ត្រីប្រហែលជាអាចទទួលបានការគំរាមគំហែង ដោយភាគីទាំងនេះ ប្រសិនបើនាងមិនបន្តដំណើរការសម្រុះសម្រួល។ នាងអាចស្ថិតក្នុងហានិភ័យខ្ពស់ពីការសងសឹក ប្រសិនបើនាង ស្នើសុំឱ្យមានការការពារ។ ជនរងគ្រោះក្នុងកាលៈទេសៈនេះ ប្រហែលជាអាចស្នើឱ្យដោះលែងជនមុខសញ្ញា ឬស្នើឱ្យទម្លាក់ បទចោទ ដោយសារតែនាងអាចគិតថា ការជួយនេះគ្រាន់តែជាដំណោះស្រាយបណ្តោះអាសន្ន ហើយនាងប្រហែលជានឹងមិនត្រូវបានធ្វើបាប ប្រសិនបើនាងគាំទ្រជាជាងប្រឆាំងនឹងដៃគូរបស់នាង។ នៅពេលដែលលទ្ធផល នៃការសម្រុះសម្រួល គឺជាការរួមរស់ជាមួយគ្នាឡើងវិញ រវាងស្ត្រីរងគ្រោះ និងជនមុខសញ្ញា អ្នកសម្រុះសម្រួលត្រូវប្រុងប្រយ័ត្នថាស្ត្រីអាចនឹងត្រូវប្រឈមមុខនឹងអំពើហិង្សាកាន់តែច្រើនថែមទៀតក្នុងកាលៈទេសៈនោះ ដោយសារតែវដ្តនៃអំពើហិង្សាដែលអាចស្ងប់ស្ងាត់មួយរយៈពេលមុនពេលកើនឡើងហិង្សាលើសមុន។ ដើម្បីធានាបាននូវសុវត្ថិភាពរបស់ស្ត្រីរងគ្រោះ ក្នុងអំឡុងពេល និងក្រោយពេលបញ្ចប់ដំណើរការសម្រុះសម្រួល វាទាមទារឱ្យមានការសម្របសម្រួលពីសំណាក់អ្នកសម្រុះសម្រួល និងអាជ្ញាធរមូលដ្ឋាន ក៏ដូចជាសេវាគាំទ្រនានា។

កត្តាសំខាន់មួយទៀតសម្រាប់ពិចារណា នោះគឺ សុវត្ថិភាពកុមារដែលរស់នៅជាមួយភាគីវិវាទ។ ការសិក្សាស្រាវជ្រាវបានបង្ហាញថា អំពើហិង្សាដោយ

### វិធានការមួយចំនួនដែល អ្នកសម្រុះសម្រួលអាចយក មកប្រើប្រាស់ ដើម្បីធានាសុវត្ថិភាព និងការពារជនរងគ្រោះ

- ❖ រាយការណ៍អំពីការគំរាមកំហែង ការបំភិតបំភ័យ ការយាយីបៀតបៀន ឬការប្រព្រឹត្តអំពើហិង្សាណាមួយ ទៅកាន់អាជ្ញាធរមានសមត្ថកិច្ច ឬអាជ្ញាធរដែលនៅជិតបំផុត ស្របតាមមាត្រា ១៣ និង ១៤ នៃច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។
- ❖ ចេញសេចក្តីសម្រេចរដ្ឋបាល ដើម្បីការពារសុវត្ថិភាពស្ត្រីរងគ្រោះ ស្របតាមមាត្រា១៤ នៃច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។
- ❖ អំពាវនាវឱ្យអាជ្ញាធរអនុវត្តច្បាប់ និងក្រុមគាំទ្ររៀបចំវិធានការសន្តិសុខសម្រាប់ស្ត្រីរងគ្រោះ។
- ❖ រៀបចំការប្រជុំដាច់ដោយឡែកជាមួយស្ត្រីរងគ្រោះ។
- ❖ លើកទឹកចិត្តស្ត្រីរងគ្រោះ ឱ្យទទួលបានជំនួយពីអ្នកអម ឬ អ្នកគាំទ្រក្នុងដំណើរការសម្រុះសម្រួលក្នុងអំឡុងពេលសម្រុះសម្រួលជាក់ស្តែង។
- ❖ ផ្អាក ឬ បញ្ឈប់ដំណើរការសម្រុះសម្រួលដែលផ្តល់សុវត្ថិភាពដល់ភាគី។

ដែគូស្និទ្ធស្នាលអាចបង្កគ្រោះថ្នាក់ដល់កុមារដោយប្រយោល ដោយសារតែការប៉ះទង្គិចផ្លូវចិត្តដែលកើតចេញពីការមើលឃើញការរំលោភបំពានទាំងនេះ និងដោយផ្ទាល់ផងដែរ ដោយសារជនមុខសញ្ញា មិនអត់ឱនឱ្យសុវត្ថិភាពកុមារ។ វាមានសារៈសំខាន់ណាស់ក្នុងការធានាថា សេចក្ដីសម្រេចរដ្ឋបាល និងដីកាការពារត្រូវបញ្ចូលវិធានសម្រាប់ការគ្រប់គ្រង និងការពារសុវត្ថិភាពកុមារ។

## ៥.៨. គោលការណ៍ឯករាជ្យភាព និងអព្យាក្រឹតភាព

អ្នកសម្រុះសម្រួលត្រូវតែមានឯករាជ្យភាព និងអព្យាក្រឹតភាព ដើម្បីជួយឱ្យភាគី ឈានទៅដល់កិច្ចព្រមព្រៀង ដែលទទួលការពេញចិត្តពីភាគីទៅវិញទៅមក។ ឯករាជ្យភាព តម្រូវឱ្យអ្នកសម្រុះសម្រួលមិនធ្វើសកម្មភាពក្រោមឥទ្ធិពលរបស់ភាគីទីបី ពេលដែលខ្លួនមកធ្វើការសម្រុះសម្រួលក្នុងដំណើរការសម្រុះសម្រួលឡើយ។

អព្យាក្រឹតភាពមានន័យថា អ្នកសម្រុះសម្រួលមិនមានភាពលំអៀងទៅរកភាគីណាមួយឡើយ។ អ្នកសម្រុះសម្រួលក៏មិនមែនជាអ្នកតស៊ូមតិឱ្យភាគីណាមួយដែរ។ ក្នុងករណីដែលមិនអាចរក្សា ឯករាជ្យភាព និងអព្យាក្រឹតភាពបាន អ្នកសម្រុះសម្រួលត្រូវបដិសេធ ឬ បញ្ឈប់ដំណើរការសម្រុះសម្រួល ដោយរៀបចំនីតិវិធីបញ្ចប់ដែលមិនបង្កគ្រោះថ្នាក់ដល់ស្ត្រីរងគ្រោះ។

## ៥.៩. គោលការណ៍រក្សាការសម្ងាត់

ដំណោះស្រាយដែលគួរជាទីពេញចិត្តចំពោះករណីវិវាទណាមួយ តម្រូវឱ្យភាគីចូលរួមនៅក្នុងដំណើរការសម្រុះសម្រួល អាចនិយាយត្រង់ៗដោយបើកចំហ និងជឿទុកចិត្ត អំពីអ្វីដែលបានកើតមានឡើង។ គោលការណ៍រក្សាការសម្ងាត់ តម្រូវឱ្យអ្នកដែលចូលរួមក្នុងដំណើរការសម្រុះសម្រួលទាំងអស់ មានកាតព្វកិច្ចរក្សាការសម្ងាត់ដោយមិនបង្ហាញព័ត៌មាន ឬ ឯកសារនានា ដែលត្រូវបានបង្ហាញក្នុងដំណើរការនៃការសម្រុះសម្រួល ទៅកាន់អ្នកដទៃ ឬ ជាទីសាធារណៈដោយមិនមានការយល់ព្រមពីភាគីទាំងពីរបានទេ។ អ្នកសម្រុះសម្រួលមានកាតព្វកិច្ចពន្យល់ទៅភាគីវិវាទ និងអ្នកចូលរួមទាំងអស់ក្នុងដំណើរសម្រុះសម្រួលអំពីគោលការណ៍រក្សាការសម្ងាត់នេះ នៅគ្រប់ដំណាក់កាលនៃការសម្រុះសម្រួល។

## ៥.១០. គោលការណ៍សមត្ថភាពអ្នកសម្រុះសម្រួល

អ្នកសម្រុះសម្រួលករណីវិវាទ ចាំបាច់ត្រូវទទួលបានការបណ្តុះបណ្តាលជំនាញឱ្យបានសមស្របអំពីវិធីសាស្រ្តធ្វើការសម្រុះសម្រួល ដែលផ្តោតសំខាន់ទៅលើការគោរពសិទ្ធិ ការគិតគូពីយេនឌ័រ និងឆ្លើយតបចំពោះយេនឌ័រ ដើម្បីអាចធ្វើការដោះស្រាយកត្តារាំងនានាដោយមានប្រសិទ្ធភាព។ អ្នកសម្រុះសម្រួលក៏ត្រូវមានចំណេះដឹង និងជំនាញ ធ្វើការងារជាមួយជនមានពិការភាពផងដែរ ហើយអ្នកសម្រុះសម្រួលត្រូវចាំថា ទម្រង់នៃពិការភាពមួយចំនួនមិនអាចមើលដឹងតាមរយៈសំបកក្រៅនោះទេ។ សម្រាប់ទម្រង់ពិការភាពទាំងនោះ ឥរិយាបថមួយចំនួន ដែលធ្វើឡើងដោយគ្មានចេតនា ក៏អាចបង្កឱ្យមានគ្រោះថ្នាក់ទៅដល់ស្រ្តីរងគ្រោះផងដែរ។[៣]

---

៣ ផ្នែកទី២ នៃគោលការណ៍ណែនាំស្តីពីការគាំទ្រផ្លូវច្បាប់ដល់ជនមានពិការភាពក្នុងប្រព័ន្ធយុត្តិធម៌ អាចផ្តល់ជាធនធានមានសារៈប្រយោជន៍ ដល់បុគ្គលិកបម្រើការងារជាមួយជនមានពិការភាព។ សូមស្វែងយល់បន្ថែមជាភាសាអង់គ្លេសនិងខ្មែរតាមរយៈ https://www.kh.undp.org/content/cambodia/en/home/library/practical-guideline-on-legal-aid-for-persons-with-disabilitiesen.html

# ៦ គោលការណ៍ណែនាំ ស្តីពីនីតិវិធីសម្រាប់ការសម្រុះសម្រួលវិវាទក្នុងបរិបទនេះ

ខាងក្រោមនេះគឺជានីតិវិធីគួរយកមកអនុវត្ត ដែលស្របទៅតាមគោលការណ៍ដែលត្រូវបានពិភាក្សាខាងលើ និងស្របទៅតាមទិដ្ឋភាពជាក់ស្តែងនៃអំពើហិង្សាលើស្ត្រី លក្ខណៈប្រែប្រួលនៃការរំលោភបំពាន និងតម្រូវការចិត្តសង្គមរបស់ស្ត្រីរងគ្រោះ ក៏ដូចជាច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សនានា។

## ៦.១. ការត្រួតពិនិត្យបឋមលើករណី មុនចាប់ផ្តើមដំណើរការសម្រុះសម្រួល

គោលបំណងនៃការត្រួតពិនិត្យបឋមលើករណីវិវាទមុនពេលដំណើរការសម្រុះសម្រួល គឺដើម្បីកំណត់ថាតើការសម្រុះសម្រួលក្នុងករណីវិវាទនេះមាននីត្យានុកូលភាពនិងភាពសមស្របដែរឬទេ។ ការត្រួតពិនិត្យបឋមលើករណីចាំបាច់ត្រូវធ្វើឡើងនៅគ្រប់ដំណាក់កាលនៃការសម្រុះសម្រួល តាំងពីពេលដែលករណីត្រូវបានបញ្ជូនចូលមកភ្លាម និងរាល់មុនពេលចាប់ផ្តើមកិច្ចប្រជុំសម្រុះសម្រួល រហូតដល់ក្រោយការសម្រុះសម្រួល។ គួរកត់សម្គាល់ថា នៅក្នុងបរិបទករណីអំពើហិង្សាពាក់ព័ន្ធផ្លូវចិត្ត និង/ឬ សេដ្ឋកិច្ច ក៏អាចមានករណីអំពើហិង្សាផ្លូវកាយ និង/ឬ ផ្លូវភេទ កើតមានឡើងដែរ ប៉ុន្តែអាចមិនត្រូវបានចែករំលែកដោយភាគីស្ត្រី។ ករណីខ្លះទៀត អំពើហិង្សាផ្លូវចិត្ត និង/ឬ សេដ្ឋកិច្ច អាចប្រែក្លាយទៅជាអំពើហិង្សាផ្លូវកាយ និង/ឬ ផ្លូវភេទយ៉ាងឆាប់រហ័សផងដែរ។ ការផ្លាស់ប្តូរទំនាក់ទំនងនៃអំណាច ឬ កាលៈទេសៈរបស់ភាគី អាចកើតមានឡើងគ្រប់ពេលដែលអ្នកសម្រុះសម្រួលចាំបាច់ត្រូវត្រួតពិនិត្យម្តងទៀតពីភាពសមស្របនិងស្របច្បាប់នៃការសម្រុះសម្រួលនោះនៅរាល់ពេលមុនចាប់ផ្តើមកិច្ចប្រជុំសម្រុះសម្រួលនិងគ្រប់ដំណាក់កាលបន្តបន្ទាប់។

ការត្រួតពិនិត្យបឋមដើម្បីកំណត់ពីកត្តានីត្យានុកូលភាពនិងភាពសមស្របនៃការសម្រុះសម្រួលវិវាទនៅមុនដំបូងនិងជាបន្តបន្ទាប់ គឺជាជំហានសំខាន់បំផុតដែលមិនអាចខ្វះបាន ដើម្បីធានាថា ភាគីនិងសមាជិកគ្រួសារដទៃទៀតមិនស្ថិតក្នុងគ្រោះថ្នាក់ រងអំពើហិង្សា ឬ ការគំរាមគំហែង និងដើម្បីធានាថាការសម្រុះសម្រួលអាចប្រព្រឹត្តទៅបានដោយសមស្របនិងស្របច្បាប់។

### នីតិវិធីសម្រាប់ការត្រួតពិនិត្យបឋមលើករណីវិវាទ៖

បន្ទាប់ពីទទួលបានពាក្យបណ្តឹងដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ អ្នកសម្រុះសម្រួលជាស្ត្រីត្រូវធ្វើការសម្ភាសន៍ជាមួយភាគីស្ត្រីភ្លាម មុនពេលអនុញ្ញាតឱ្យគាត់ចាកចេញត្រឡប់ទៅវិញ ដើម្បី

វាយតម្លៃជាបឋម ថាតើការសម្រុះសម្រួលលើវិវាទនេះ មាននីត្យានុកូលភាពនិងភាពសមស្រប ដែរឬទេ ដោយប្រើប្រាស់ទម្រង់កម្រងសំណួរត្រួតពិនិត្យបឋម (សូមមើលឧបសម្ព័ន្ធទី ១)។ អ្នកសម្រុះសម្រួលត្រូវរៀបចំកិច្ចប្រជុំបឋមនេះ ជាមួយភាគីស្ត្រី ឬ រួមគ្នាជាមួយអ្នកគាំទ្រ (បើមាន) ក្នុងករណីដែលអាចធ្វើទៅបាន។ កិច្ចប្រជុំបឋមនេះគួរធ្វើឡើងដាច់ដោយឡែកក្នុងបន្ទប់ ឬ កន្លែងសុវត្ថិភាពណាដែលមិនមាននរណាអាចស្តាប់ឮ។ នីតិវិធីត្រួតពិនិត្យបឋមលើករណីវិវាទនេះ គឺផ្តោតសំខាន់ទៅលើការកំណត់អំពីស្ថានភាពសន្តិសុខ ភាពភ័យខ្លាច ទម្រង់នៃអំពើហិង្សានានា គោលបំណងរបស់ភាគីស្ត្រីក្នុងការសម្រុះសម្រួល និងសមត្ថភាពក្នុងការចូលរួមដោយសេរី ចរចាដោយស្មើភាព និងសម្រេចចិត្តដោយខ្លួនឯង។

អ្នកសម្រុះសម្រួល គប្បីប្រើប្រាស់កម្រងសំណួរត្រួតពិនិត្យបឋម សម្រាប់គ្រប់ករណីវិវាទទាំងអស់ ទោះក្នុងករណីដែលអ្នកសម្រុះសម្រួលបានយល់ដឹងពីប្រវត្តិនៃអំពើហិង្សា ឬ មិនទាន់បានដឹងក៏ដោយ។ ការសិក្សាស្រាវជ្រាវរបស់ក្រសួងកិច្ចការនារីឆ្នាំ២០១៥ បានបង្ហាញថា ស្ត្រីភាគច្រើនដែលរងគ្រោះដោយអំពើហិង្សា មិនងាយស្វែងរកជំនួយឬបង្ហាញពីអំពើហិង្សាដែលខ្លួនទទួលរងទៅនរណាម្នាក់នោះទេ ទោះក្នុងករណីធ្ងន់ធ្ងរក៏ដោយ។ ៥៨% នៃស្ត្រីដែលទៅស្វែងរកសេវាសុខភាពដែលមានពាក់ព័ន្ធនឹងស្នាមរបួស មិនបានប្រាប់អំពីមូលហេតុនៃរបួសទៅកាន់អ្នកផ្តល់សេវាសុខភាពនោះទេ។ ៤៩% នៃស្ត្រីដែលរងគ្រោះដោយអំពើហិង្សាផ្លូវកាយនិងផ្លូវភេទ មិនបានប្រាប់នរណាម្នាក់អំពីហិង្សាដែលកើតឡើងលើខ្លួននោះទេ។ ចំណែកឯស្ត្រី ដែលហ៊ានប្រាប់បញ្ហារបស់ខ្លួនគឺជ្រើសរើសប្រាប់តែមិត្តភក្តិ សាច់ញាតិ ឬ អ្នកជិតខាងរបស់ខ្លួនប៉ុណ្ណោះ ជាជាងអាជ្ញាធរមានសមត្ថកិច្ច មន្ត្រីនគរបាល គ្រូពេទ្យ ឬ មន្ត្រីអង្គការមិនមែនរដ្ឋាភិបាល។ ដូចនេះ ហានិភ័យក្នុងដំណើរការសម្រុះសម្រួលដោយមិនបានយល់ដឹងពីបទពិសោធនៃអំពើហិង្សាដែលស្ត្រីកំពុងជួបប្រទះអាចមានអាត្រាខ្ពស់។

**កម្រងសំណួរត្រួតពិនិត្យបឋមលើករណីវិវាទ អាចមានដូចខាងក្រោម៖**

- តើភាគីម្ខាងទៀតបានសម្លុតគំរាមគំហែងប្រើប្រាស់ហិង្សានិងបង្កគ្រោះថ្នាក់ដល់អ្នក ឬ អ្នកដែលជិតដិតនឹងអ្នកដែរឬទេ?
- តើអ្នកមានភាពភ័យខ្លាចចំពោះសុវត្ថិភាពខ្លួន ឬ កូនក្មេងដែរឬទេ?
- តើអ្នកជ្រើសរើសការសម្រុះសម្រួលនេះ ដោយស្ម័គ្រចិត្តនិងមិនមានការបង្ខិតបង្ខំមែនទេ?
- តើអ្នកមានអ្វីចង់សួរខ្ញុំ ឬ ចង់ប្រាប់ខ្ញុំដែរឬទេ មុនពេលយើងបន្តដំណើរការ?

ក្នុងកាលៈទេសៈខ្លះ ភាគីមិនហ៊ានបង្ហាញពីការរំលោភបំពាននានា ឬក៏ត្រូវបានគំរាមគំហែងមិនអោយរាយការណ៍ករណីអំពើហិង្សា។ ដូចនេះ អ្នកសម្រុះសម្រួលត្រូវពិចារណាផងដែរនូវភាសាកាយវិការនិងប្រតិកម្មនានាអំឡុងពេលកិច្ចសម្ភាសន៍ត្រួតពិនិត្យបឋម។

**បន្ទាប់ពីសាកសួរភាគីទាំងពីររួច អ្នកសម្រុះសម្រួល ក៏ត្រូវសួរខ្លួនឯងនូវសំណួរខាងក្រោម៖**

- តើខ្ញុំគិតថា ភាគីម្ខាងទៀតកំពុងបំភិតបំភ័យ ឬ អាចបង្កគ្រោះថ្នាក់ដល់ភាគីស្ត្រីដែរឬទេ?
- តើខ្ញុំគិតថា ការសម្រុះសម្រួលអាចឆ្លើយតបទៅនឹងគោលបំណងរបស់ភាគីស្ត្រីដែរឬទេ?
- តើអ្នកមានអ្វីចង់សួរខ្ញុំ (អ្នកសម្រុះសម្រួល) ឬ ចង់ប្រាប់ខ្ញុំដែរឬទេ មុនពេលយើងបន្តដំណើរការ?
- តើខ្ញុំគិតថា ភាគីស្ត្រីអាចធ្វើការចូលរួមក្នុងដំណើរការសម្រុះសម្រួលដោយសេរី ស្មើភាព និងគ្មានការបង្ខិតបង្ខំដែរឬទេ?

អ្នកសម្រុះសម្រួល ត្រូវពិភាក្សាក្នុងក្រុមអ្នកសម្រុះសម្រួលរបស់ខ្លួន ទៅលើចម្លើយដែលទទួលបានចេញពីការត្រួតពិនិត្យបឋមនេះ ហើយត្រូវកំណត់ពីហានិភ័យផ្សេងៗដែលអាចកើតមានទៅលើភាគីស្ត្រី មុនឈានទៅសម្រេចថាតើ ដំណើរការសម្រុះសម្រួលអាចប្រព្រឹត្តទៅបានដែរឬយ៉ាងណា។

**ខាងក្រោមនេះ គឺជាជំហានណែនាំសម្រាប់អ្នកសម្រុះសម្រួលបន្ទាប់ពីធ្វើការត្រួតពិនិត្យបឋមលើករណីរួច៖**

### ៦.១.១. ករណីការសម្រុះសម្រួលលើវិវាទមិនមាននីត្យានុកូលភាពនិងភាពសមស្រប

ប្រសិនបើ នៅក្នុងដំណើរការត្រួតពិនិត្យករណីបឋមខាងលើ រកឃើញថា ភាគីស្ត្រីមានការភិតភ័យមិនអាចចូលរួមដោយស្មើភាព និងសេរី ឬ មានឧបសគ្គផ្សេងៗក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯងបាន ឬ ធ្លាប់មានអំពើហិង្សា ឬ ការរំលោភបំពានបានកើតឡើង ឬ កំពុងកើត ឬ អាចបន្តកើតមាន ដែលបង្កជាបទមជ្ឈិមឬឧក្រិដ្ឋ ឬប៉ះពាល់ដល់សិទ្ធិ និងសុវត្ថិភាពរបស់ពួកគេ ដំណើរការសម្រុះសម្រួលមិនមាននីត្យានុកូលភាព និង/ឬ ភាពសមស្របក្នុងការយកមកប្រើប្រាស់សម្រាប់ដោះស្រាយលើករណីវិវាទនេះឡើយ។ ក្នុងករណីនេះ អ្នកសម្រុះសម្រួលមិនបញ្ជូនជនរងគ្រោះទៅផ្ទះ

វិញភ្លាមនោះទេ។ អ្នកសម្រុះសម្រួលមានកាតព្វកិច្ចក្នុងការផ្តល់ព័ត៌មាន និងសេវាជំនួយនានាដល់ភាគីស្ត្រី ក៏ដូចជា វិធានការនីតិវិធីដែលសមស្របផ្សេងៗ ក្នុងគោលបំណងការពារទប់ស្កាត់មិនឱ្យកើតមានអំពើហិង្សា និងធានាថា ភាគីស្ត្រីមានសុវត្ថិភាព និងការគាំទ្រគ្រប់គ្រាន់ ស្របទៅតាមគោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រី និងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ របស់ក្រសួងកិច្ចការនារី ឆ្នាំ២០១៦។

- ត្រូវណែនាំ ភាគីស្ត្រីរងគ្រោះឱ្យដឹងអំពីសិទ្ធិរបស់ខ្លួន និងច្បាប់ពាក់ព័ន្ធដែលការពារនាង។
- ផ្តល់ការប្រឹក្សាជាមូលដ្ឋាន ស្របទៅនឹងបទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រី និងក្មេងស្រីជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ។
- ចង្អុលបង្ហាញស្ត្រីរងគ្រោះ ពីសេវាជំនួយផ្សេងៗ ដូចជា មណ្ឌលសុខភាព ការថែទាំសុខភាពជាបន្ទាន់ សេវាសង្គម និងប្រឹក្សាផ្លូវចិត្ត និង ផ្លូវច្បាប់ផ្សេងៗ ។ល។
- ស្នើសុំសេចក្តីសម្រេចរដ្ឋបាលឃុំ ស្របតាមមាត្រា១៤ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដើម្បីផ្តល់សុវត្ថិភាពដល់ស្ត្រីនិងកូនក្នុងបន្ទុក។
- បញ្ជូនស្ត្រីរងគ្រោះទៅរកជម្រកសុវត្ថិភាព ឬ ស្នាក់នៅផ្ទះសាច់ញាតិ មិត្តភក្តិ ឬ កន្លែងសុវត្ថិភាពផ្សេងទៀតតាមជម្រើសរបស់នាង។
- ប្រាប់អំពីសិទ្ធិដល់ស្ត្រីរងគ្រោះក្នុងការដាក់ពាក្យសុំដីកាការពារនៅតុលាការ។
- ស្នើសុំឱ្យមានអន្តរាគមន៍ ឬ ចំណាត់ការមានប្រសិទ្ធភាពនានាពីអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ការពារមិនឱ្យមានអំពើហិង្សាឬការគំរាមកំហែង និងត្រូវធានាថាជនរងគ្រោះមានសុវត្ថិភាព។
- ក្នុងករណីភាគីស្ត្រីរងគ្រោះមិនស្នើសុំឱ្យមានការចោទប្រកាន់ និងផ្តន្ទាទោសជនមុខសញ្ញា អ្នកសម្រុះសម្រួល ត្រូវបញ្ជូនករណីនេះទៅកាន់នគរបាល ឬ អាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់ចែងតាមនីតិវិធីបន្ត។

ខាងក្រោមនេះ ជានីតិវិធីមួយចំនួនសម្រាប់ការអន្តរាគមន៍ និងបញ្ជូនបន្ត៖

### ៦.១.២. ករណីការសម្រុះសម្រួលលើវិវាទមាននីត្យានុកូលភាព និងភាពសមស្រប

ប្រសិនបើដំណើរការត្រួតពិនិត្យបឋមលើករណីវិវាទ បង្ហាញថា ភាគីស្ត្រីមិនមានការភ័យខ្លាច ឬ មិនមានអំពើហិង្សា ការរំលោភបំពានណាមួយ កំពុងឬអាចកើតមានឡើងនោះទេ ហើយភាគីស្ត្រីនៅតែទទូច និងមានបំណងចង់ឱ្យមានការសម្រុះសម្រួល ដោយបង្ហាញពីស្ថានភាពដែលខ្លួនអាចធ្វើសេចក្តីសម្រេចចិត្តដោយសេរីនិងដោយស្មើភាពបាន អ្នកសម្រុះសម្រួល អាចបន្តដំណើរការសម្រុះសម្រួលបាន។ ការសម្រុះសម្រួល អាចបន្តទៅមុខបាន នៅពេលដែលលក្ខខណ្ឌដូចខាងក្រោមត្រូវបានបំពេញ៖

#### ១. អ្នកសម្រុះសម្រួលត្រូវផ្តល់ឱ្យភាគីស្ត្រីនូវព័ត៌មានជាមុន អំពីជម្រើសនានា និងដំណើរការនៃការសម្រុះសម្រួល

ការយល់ដឹងពីដំណើរការសម្រុះសម្រួលជាមុន និងជាពិសេសពីជម្រើសនានាដែលអាចមានគឺមានសារៈសំខាន់ណាស់សម្រាប់ភាគីស្ត្រី។ ភាគីស្ត្រីត្រូវការព័ត៌មានគ្រប់គ្រាន់សម្រាប់ការសម្រេចចិត្តថាតើគួរជ្រើសរើសយកការសម្រុះសម្រួលដែរឬទេ។ ជាពិសេសក្នុងករណីនាងនៅបន្តជ្រើសយកការសម្រុះសម្រួល នោះនាងអាចបានរៀបចំខ្លួនសម្រាប់ដំណើរការសម្រុះសម្រួលនេះ។ ការយល់ដឹងបែបនេះមានសារៈសំខាន់ណាស់ ដោយសារបញ្ហាអតុល្យភាពអំណាច ដែលតែងតែកើតមានជារឿយៗរវាងភាគីដៃគូស្និទ្ធស្នាល។ ភាគីស្ត្រីគួរត្រូវបានផ្តល់ព័ត៌មានជាមុន អំពីដំណើរការសម្រុះសម្រួលដូចខាងក្រោម៖

- តើការសម្រុះសម្រួលជាអ្វី ហើយនឹងធ្វើឡើងទៅលើអ្វី?
- តើនឹងមានអ្វីកើតឡើងក្នុងអំឡុងពេលដំណាក់កាលសម្រុះសម្រួលនីមួយៗ?
- លទ្ធផលដែលនឹងអាចកើតចេញពីការសម្រុះសម្រួល (ដែលលទ្ធផលនោះមិនអាចជាការផ្តន្ទាទោសនរណាម្នាក់នោះទេ ប៉ុន្តែអាចជាកិច្ចព្រមព្រៀង ឬ មិនព្រមព្រៀងទៅលើដំណោះស្រាយបញ្ហាដែលភាគីជាអ្នកលើកឡើងនិងជាអ្នកសម្រេចដោយខ្លួនឯង)។

បន្ទាប់ពីពន្យល់ប្រាប់ពីដំណើរការសម្រុះសម្រួលរួច អ្នកសម្រុះសម្រួលគួរបញ្ជាក់ភាគីស្ត្រីម្តងទៀតពីការយល់ច្បាស់របស់នាងលើដំណាក់កាលនីមួយៗនៃការសម្រុះសម្រួលនេះ ថាតើនាងមានចម្ងល់អ្វីទេ និងថាតើនាងនៅតែបន្តស្ម័គ្រចិត្តចូលរួមការសម្រុះសម្រួលដោយគ្មានការបង្ខិតបង្ខំ។

ក្នុងករណីនាងបន្តជ្រើសរើសយកដំណើរការសម្រុះសម្រួលនោះភាគីស្ត្រីអាចធ្វើការសម្រេចចិត្តទទួលៈ

- ❖ ជំនួយពីអ្នកតំណាងឱ្យខ្លួនក្នុងការសម្រុះសម្រួល និងអ្នកដែលផ្តល់ការគាំទ្រម្នាក់ទៀត ដែលមិនមានការជះឥទ្ធិពលអវិជ្ជមានដល់ខ្លួន។
- ❖ ធ្វើការពិភាក្សាជាមួយអ្នកទាំងនោះអំពីរបៀបវារៈ ដែលភាគីស្ត្រីលើកយកមកពិភាក្សាក្នុងអំឡុងពេលនៃការសម្រុះសម្រួល ក្នុងករណីអាចសម្រុះសម្រួលបាន។

ការផ្តល់ព័ត៌មានជាមុនអំពីដំណើរការសម្រុះសម្រួលបែបនេះ អាចធ្វើឡើងតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់។ ប៉ុន្តែជម្រើសដែលល្អបំផុតគឺ សន្ធានការី ឬ អ្នកសម្រុះសម្រួលជាស្ត្រីត្រូវជួបជាមួយភាគីស្ត្រីដោយផ្ទាល់ ឬ រួមជាមួយនឹងអ្នកគាំទ្រឱ្យភាគីស្ត្រីតែម្តង។

**២. អ្នកសម្រុះសម្រួលត្រូវធានាថា ភាគីស្ត្រីដឹងពីសិទ្ធិរបស់ខ្លួន មុនចាប់ផ្តើមកិច្ចប្រជុំសម្រុះសម្រួល។**

**៣. ភាគីវិវាទយល់ព្រមចូលរួមក្នុងការសម្រុះសម្រួល និងផ្តល់ការព្រមព្រៀងចំពោះការសម្រុះសម្រួល។**

**៤. ភាគីស្ត្រីអាចបន្តឡើងនិយាយចរចាដោយស្មើភាពខ្លួនឯង ដោយសេរីនិងគ្មានការបង្ខិតបង្ខំនិងជាពិសេស ដោយគ្មានឧបសគ្គរាំងក្នុងការសម្រេចចិត្តទៅលើដំណើរការនិងលទ្ធផល នៃការសម្រុះសម្រួលឡើយ។**

**៥. ភាគីវិវាទ ជាពិសេសភាគីស្ត្រី មានអារម្មណ៍សុវត្ថិភាព អំឡុងពេលសម្រុះសម្រួល និងក្រោយពេលសម្រុះសម្រួល។ អ្នកសម្រុះសម្រួលអាចសួរទៅកាន់ភាគីស្ត្រីថាៈ តើអ្នកមានកង្វល់ ឬ ការព្រួយបារម្ភអ្វីទេ ក្នុងការដែលអង្គុយរួមតុជាមួយភាគី "ឈ្មោះភាគីម្ខាងទៀត"? បើមាន តើអ្នកត្រូវការអង្គុយបន្ទប់ដាច់ដោយឡែកពីភាគីម្ខាងទៀតដែរឬទេ? ឬតើអ្នកត្រូវការអ្នកអមដែរឬទេ?**

**៦. ការសម្រុះសម្រួល គួរត្រូវបានធ្វើឡើងនៅកន្លែងដែលភាគីស្ត្រីមានអារម្មណ៍សុវត្ថិភាព។ ការសម្រុះសម្រួលត្រូវធ្វើឡើងនៅទីតាំងអព្យាក្រឹតដែលមិនមានការរំខានពីខាងក្រៅ និងអ្នកដែលមិនពាក់ព័ន្ធនឹងដំណើរការសម្រុះសម្រួល។**

**៧. អ្នកសម្រុះសម្រួល ត្រូវត្រៀមរៀបចំជាមុននូវកិច្ចព្រមព្រៀងចូលរួមក្នុងការសម្រុះសម្រួល បទបញ្ជា**

ផ្ទៃក្នុង និងរក្សាការសម្ងាត់ និងកំណត់ពេលធ្វើការសម្រុះសម្រួល និងទីកន្លែងសម្រុះសម្រួល។

៨. ភាគីវិវាទ ត្រូវបានណែនាំពាក់ព័ន្ធនឹងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងច្បាប់ពាក់ព័ន្ធ។

## ៦.២. អំឡុងពេលដំណើរការសម្រុះសម្រួល

ទីតាំងសម្រុះសម្រួលជាលក្ខខណ្ឌចាំបាច់សំខាន់។ វាគួរតែជាទីតាំងដែលមានលក្ខណៈអព្យាក្រឹតភាព (មិនមែនជាផ្ទះរបស់ភាគីណាមួយ ហើយក៏មិនមែនជាផ្ទះសាច់ញាតិ របស់ភាគីណាមួយ ហើយក៏មិនមែនជាកន្លែងធ្វើការរបស់បុគ្គលពាក់ព័ន្ធណាមួយ)។ ក្នុងលក្ខខណ្ឌដែលអាចធ្វើបាន ការសម្រុះសម្រួលបែបត្រល់គួរត្រូវបានធ្វើឡើង ដែលភាគីស្ថិតក្នុងបន្ទប់ផ្សេងគ្នាសម្របសម្រួលដោយអ្នកសម្រុះសម្រួល ដើម្បីធានាថា ភាគីមានសេរីភាពក្នុងការនិយាយជាមួយអ្នកសម្រុះសម្រួល និងអាចបង្ហាញនូវការចង់បានរបស់ខ្លួន ដោយគ្មានការបំភិតបំភ័យ ឬ គាបសង្កត់។ បើភាគីចូលក្នុងបន្ទប់តែមួយ ដើម្បីសម្រុះសម្រួល វាគប្បីជាបន្ទប់ដែលមានតុកៅអី តែមិនមានវត្ថុ ឬ សម្ភារមុតស្រួចដែលអាចបង្កគ្រោះថ្នាក់ នៅជិតនោះទេ។ គប្បីរៀបចំឱ្យភាគីទាំងពីរអង្គុយឃ្លាតឆ្ងាយពីគ្នា តាមដែលអាចធ្វើបាន។ ម្យ៉ាងទៀតបើអាច គប្បីណាត់ម៉ោងឱ្យភាគីទាំងពីរមកដល់ និងចាកចេញខុសគ្នាបន្តិច ដើម្បីបញ្ចៀសការប្រាស្រ័យទាក់ទងគ្នារវាងភាគីឱ្យកាន់តែតិចកាន់តែល្អ។ ការសម្រុះសម្រួលក្នុងបរិបទនេះ ចាំបាច់ត្រូវមានអ្នកសម្រុះសម្រួលពីរនាក់ជាស្ត្រី និងបុរស។

យ៉ាងណាមិញ ទោះបីជាការត្រួតពិនិត្យករណីបឋម រកមិនឃើញមានអំពើហិង្សា ការភ័យខ្លាច ឬ ការរំលោភបំពានក៏ដោយ អ្នកសម្រុះសម្រួល គួរបន្តពិនិត្យមើលនៅគ្រប់ដំណាក់កាលនៃដំណើរការសម្រុះសម្រួល ដោយសារអំពើហិង្សាដោយដៃគូស្និទ្ធស្នាល គឺអាចមានករណីនាំឱ្យអំណាចមិនស្មើគ្នា និងការត្រួតត្រាលើដៃគូ ការរំលោភបំពានអាចលេចឡើង ឬ កើនឡើងនៅពេលដែលដៃគូម្ខាងទៀតយល់ថាខ្លួនបាត់បង់ការត្រួតត្រា។ ដូច្នេះអាកប្បកិរិយារំលោភបំពានអាចនឹងលេចឡើង នៅពេលដែលដំណើរការសម្រុះសម្រួលកំពុងប្រព្រឹត្តទៅ។ ភាគីបុរស អាចបង្ហាញពីការសហការចូលរួមក្នុងដំណើរការសម្រុះសម្រួលនៅពេលដំបូង ប៉ុន្តែបន្ទាប់មកបានប្តូរទៅជាបញ្ចេញអាកប្បកិរិយាបង្ខិតបង្ខំ ឬ ប្រើប្រាស់ភាសាកាយវិការផ្សេងៗបែបគំរាមកំហែងណាមួយ ប្រសិនបើ គាត់មិនអាចសម្រេចបានទិសដៅរបស់ខ្លួន។ ជាពិសេស

ក្នុងករណីដែល ដំណើរការសម្រុះសម្រួលចំណាយរយៈពេលយូរ ដែលអាចជាកាលៈទេសៈមួយបណ្តាលឱ្យមានឧបាយកលរំលោភបំពានលេចឡើង ឬ កើនឡើង។

ក្នុងករណីអ្នកសម្រុះសម្រួលអង្កេតឃើញពីភាពស្ទាក់ស្ទើរ អាកប្បកិរិយាមិនប្រក្រតី ឬកង្វល់ណាមួយរបស់ភាគីស្ត្រីកើតឡើងអំឡុងពេលសម្រុះសម្រួល ព្រមទាំង សកម្មភាពឬកាយវិការបំភិតបំភ័យ ដាក់សម្ពាធ ប្រើអំណាចគ្រប់ដណ្តប់ និងចាប់បង្ខំណាមួយដោយភាគីបុរស ឬ ភាគីទីបី រួមទាំងសមាជិកគ្រួសាររបស់ភាគីស្ត្រី អ្នកសម្រុះសម្រួលត្រូវផ្អាកការសម្រុះសម្រួលសិន រួចពិចារណាពីជំហានបន្ទាប់ ដែលរួមមាន ការរៀបចំវគ្គប្រជុំដាច់ដោយឡែកជាមួយភាគីស្ត្រី។ ការប្រជុំដាច់ដោយឡែកនេះមិនគួរមានវត្តមានភាគីទីបី ឬ គួរស្នើសុំឱ្យអ្នកអម ឬ អ្នកគាំទ្រជួយភាគីស្ត្រី ដើម្បីបញ្ជាក់សាកសួរភាគីស្ត្រីពីកង្វល់និងការព្រួយបារម្ភនានារបស់នាង។ នេះជាវិធានការមួយដើម្បីបន្តពិនិត្យមើលពីភាពសមស្របនៃដំណើរការសម្រុះសម្រួលលើករណីវិវាទនេះ។

ក្នុងករណីនេះ អ្នកសម្រុះសម្រួលគួរបន្តសួរខ្លួនឯងនូវសំណួរខាងក្រោម៖

- តើខ្ញុំគិតថា ភាគីម្ខាងទៀត កំពុងតែបំភិតបំភ័យភាគីស្ត្រីដែរឬទេ?
- តើខ្ញុំគិតថា ការបន្តដំណើរសម្រុះសម្រួលនេះអាចបង្កគ្រោះថ្នាក់ ឬ ជាហានិភ័យដល់ស្ត្រីដែរ ឬទេ?
- តើខ្ញុំគិតថា ភាគីស្ត្រីអាចបន្តឡើងនិយាយចរចាដោយស្មើភាពខ្លួនឯង ដោយសេរី និងគ្មានការបង្ខិតបង្ខំ និងជាពិសេស ដោយគ្មានឧបសគ្គរារាំងក្នុងការសម្រេចចិត្តទៅលើដំណើរការ និងលទ្ធផលនៃការសម្រុះសម្រួលដែរឬទេ?

ក្នុងករណីដែលស្ថានភាពបែបនេះនៅតែបន្ត ដោយមិនអាចអនុញ្ញាតឱ្យមានការចូលរួមដោយសេរី ដំណើរការសម្រុះសម្រួលត្រូវបញ្ឈប់តែម្តង។ ក្នុងករណីនេះ អ្នកសម្រុះសម្រួលត្រូវបញ្ជូនស្ត្រីទៅរកអ្នកផ្តល់សេវាពាក់ព័ន្ធនានា និងណែនាំផ្តល់ព័ត៌មានដល់ភាគីស្ត្រីអំពីនីតិវិធីបន្ត ដើម្បីធានាថា ភាគីស្ត្រីរងគ្រោះមានសុវត្ថិភាព និងការគាំទ្រគ្រប់គ្រាន់ ស្របទៅតាមគោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រីនិងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដូចបានរៀបរាប់ក្នុងចំណុច ៦.១.១ "ករណីការសម្រុះសម្រួលលើវិវាទមិនមាននីត្យានុកូលភាព និងភាពសមស្រប" ខាងលើ។

## ប្រការត្រូវធ្វើ

- ត្រូវធានាថា កិច្ចប្រជុំសម្រុះសម្រួលត្រូវធ្វើឡើងនៅទីកន្លែងដែលអាចធានាបាននូវភាពជាឯកជន និងរក្សាការសម្ងាត់នៃការពិភាក្សា។ នៅក្នុងករណីដែលភាគីស្ត្រីជាជនមានពិការភាព អ្នកសម្រុះសម្រួលត្រូវធានាថា ទីកន្លែងសម្រុះសម្រួលនេះងាយស្រួលចេញចូលសម្រាប់ភាគីស្ត្រីទៅតាមលក្ខណៈពិការភាពរបស់គាត់។
- ត្រូវបន្តត្រួតពិនិត្យ និងធានាថា ភាគីស្ត្រីអាចបន្តចូលរួមនៅក្នុងកិច្ចប្រជុំសម្រុះសម្រួលដោយសេរី និងដោយស្ម័គ្រចិត្ត។
- ត្រូវធានាថា គូភាគីនីមួយៗ ជាពិសេសភាគីស្ត្រី មានឱកាសស្មើភាពគ្នាក្នុងការលើកឡើងពីមតិយោបល់របស់ខ្លួន។
    - អ្នកសម្រុះសម្រួលត្រូវតែពិនិត្យមើលស្ថានភាពអារម្មណ៍របស់ភាគីស្ត្រី ដើម្បីធានាថានាងមានអារម្មណ៍សុវត្ថិភាពក្នុងការនិយាយ។ អ្នកសម្រុះសម្រួល អាចនិយាយជាមួយនាង ឬ អ្នកគាំទ្រជាលក្ខណៈឯកជនដាច់ដោយឡែក មុនពេលប្រជុំសម្រុះសម្រួល ដើម្បីកំណត់ពីអារម្មណ៍សុវត្ថិភាពនេះ។
    - កំណត់បទបញ្ជាផ្ទៃក្នុងនៅពេលចាប់ផ្តើមថា អ្នកចូលរួមគ្រប់គ្នានឹងមានឱកាសនិយាយស្មើគ្នា ហើយត្រូវបន្ទំលឹកភាគីផងដែរ។
- ត្រូវធានាថា សិទ្ធិរបស់ភាគីស្ត្រីត្រូវបានគោរព និងការពារក្នុងដំណើរការសម្រុះសម្រួល។ រាល់ទម្រង់នៃ ការមិនគោរព ការបំភិតបំភ័យ ឬ ទង្វើគំរាមគំហែងផ្សេងៗមកលើភាគីស្ត្រី ត្រូវបានហាមឃាត់។
- ត្រូវធានាថា ភាគីស្ត្រីមានផាសុកភាពនៅក្នុងការប្រជុំសម្រុះសម្រួល៖ នៅកន្លែងដែលមានសញ្ញាបង្ហាញថាភាគីស្ត្រី មានអារម្មណ៍មិនស្រួល ឬ មានអារម្មណ៍រំជួលចិត្ត សូមចាត់វិធានការដើម្បីកំណត់រក និង ដោះស្រាយមូលហេតុនៃភាពមិនស្រួល ឬ អារម្មណ៍តានតឹងរបស់នាង។ បញ្ឈប់ការប្រជុំសម្រុះសម្រួលប្រសិនបើចាំបាច់។
- ត្រូវអនុញ្ញាតឱ្យភាគីស្ត្រីនិយាយដោយសេរី និងបញ្ចេញមតិ និងអារម្មណ៍ ដោយធានាថា

ការពិភាក្សាក្នុងការសម្រុះសម្រួលមិនពាក់ព័ន្ធនឹងការស្តីបន្ទោសជនរងគ្រោះឡើយ។

- ត្រូវសង្ខេបពីអ្វីដែលបានពិភាក្សាគ្នានៅចុងបញ្ចប់នៃកិច្ចប្រជុំការសម្រុះសម្រួល។ រាប់បញ្ចូលនូវអ្វីដែលចាំបាច់ដែលត្រូវពិភាក្សាបន្ថែមទៀតនៅក្នុងកិច្ចប្រជុំការសម្រុះសម្រួលលើកក្រោយទៀត រួមទាំងបញ្ហា និងសំណូមពរដែលភាគីត្រូវគិត និងសម្រេចចិត្តជាមុន មុនការប្រជុំសម្រុះសម្រួលបន្ទាប់។
- អ្នកសម្រុះសម្រួលត្រូវរៀបចំកំណត់ហេតុនិងអានកំណត់ហេតុនោះជូនភាគីទាំងសងខាង។
- ត្រូវធានាថាកិច្ចព្រមព្រៀងរបស់ភាគី (ប្រសិនបើមាន) ត្រូវបានចងក្រងជាឯកសារចុះហត្ថលេខា រក្សាទុកនៅកន្លែងមានសុវត្ថិភាព និងផ្តល់ជូនដល់ភាគី។ ធានាថាភាគីជាពិសេសភាគីស្ត្រី យល់ពីលក្ខខណ្ឌនៃ កិច្ចព្រមព្រៀង សារៈសំខាន់ និងផលវិបាកជាពិសេសនាងបានយល់ព្រមលើកិច្ចព្រមព្រៀងនោះដោយស្ម័គ្រចិត្ត និងដោយសេរី។

# ប្រការមិនត្រូវធ្វើ

- មិនត្រូវទទួលយកឥរិយាបថខុសឆ្គងក្នុងអំឡុងពេលកិច្ចប្រជុំសម្រុះសម្រួល ដូចជា ការជក់បារី ការដាក់ជើងលើតុ ការស្រែកជេរប្រមាថ និងការគំរាមកំហែងដោយភាសា ឬកាយវិការ ជាដើម។

- មិនត្រូវអនុញ្ញាតឱ្យភាគីណាមួយត្រួតត្រាលើការពិភាក្សា។

- មិនត្រូវស្តីបន្ទោសភាគីស្ត្រី នៅពេលដែលនាងត្រូវបានគេបង្គាប់ឱ្យផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេដើម្បីគេចផុតពីអំពើហិង្សា ដែលមានបង្កប់ផ្នត់គំនិតយេនឌ័រអវិជ្ជមាន។ ឧទាហរណ៍ ស្ត្រីមិនគួរត្រូវបានគេប្រាប់ថា ពួកគេមិនអាចស្តីបន្ទោសប្តីរបស់ពួកគេ នៅពេលដែលប្តីពួកគេត្រឡប់មកផ្ទះដោយភាពស្រវឹង ដើម្បីកុំធ្វើឱ្យប្តីខឹង និងប្រើអំពើហិង្សានោះឡើយ។ ស្ត្រីមិនគួរត្រូវបានគេប្រាប់ឱ្យព្រមធ្វើម្ហូបឱ្យបានទាន់ពេលវេលា មើលថែទាំផ្ទះសម្បែងឱ្យបានល្អ និងមិនត្រូវត្អូញត្អែរនៅពេលដែលប្តីកុហក ឬ លេងល្បែងឡើយ។ ទាំងនេះគឺជាឧទាហរណ៍នៃការស្តីបន្ទោសដែលផ្អែកលើផ្នត់គំនិតយេនឌ័រអវិជ្ជមាន។ ការផ្តល់យោបល់ទាំងនេះគឺជាជំនឿមិនត្រឹមត្រូវ។

- មិនត្រូវប្រញាប់ប្រញាល់ឱ្យភាគី ជាពិសេសភាគីស្ត្រី ធ្វើការសម្រេចចិត្តក្នុងអំឡុងពេលប្រជុំសម្រុះសម្រួល។ ត្រូវទុកពេលឱ្យភាគីស្ត្រីគិតនិងពិភាក្សាជាមួយអ្នកដែលនាងទុកចិត្ត ដើម្បីអាចទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយលើបញ្ហា និងសំណើដែលបានលើកឡើង មុនពេលសាកសួរពីការសម្រេចចិត្តរបស់នាង។ បើចាំបាច់ សូមស្នើឱ្យមានកិច្ចប្រជុំសម្រុះសម្រួលម្តងទៀត។

## ៦.៣. ក្រោយការសម្រុះសម្រួល

ការពិនិត្យតាមដានការគោរពទៅតាមកិច្ចព្រមព្រៀងនៃការសម្រុះសម្រួល មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យការសម្រុះសម្រួលអាចបំពេញទៅតាមសិទ្ធិរបស់ស្ត្រីក្នុងការទទួលបានយុត្តិធម៌ និងកាតព្វកិច្ចរបស់រដ្ឋ ក្នុងការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រីប្រកបដោយភាពត្រឹមត្រូវ។ ប្រព័ន្ធត្រួតពិនិត្យតាមដានមួយ ចាំបាច់ត្រូវបង្កើតឡើងដោយធានាឱ្យបាននូវសុវត្ថិភាពនិងឯកជនភាពរបស់ស្ត្រី។ ការត្រួតពិនិត្យតាមដានអាចធ្វើឡើងរៀងរាល់ ២សប្តាហ៍ម្តង ឬ ច្រើនជាងនេះទៅតាមស្ថានភាពចាំបាច់នៃករណី។ នៅពេលដែលស្ថានភាពមានភាពប្រសើរជាងមុនហើយភាគីស្ត្រីយល់ព្រម ការពិនិត្យតាមដានអាចធ្វើឡើងរៀងរាល់ ៣ ទៅ ៦ ខែម្តង។ ក្នុងករណីភាគីមិនគោរពទៅតាមកិច្ចព្រមព្រៀង ហើយបង្កអំពើហិង្សាណាមួយរួមទាំងអំពើហិង្សាលើសមាជិកគ្រួសារ និងកូនក្មេង អ្នកសម្រុះសម្រួលត្រូវបញ្ជូនសំណុំរឿងនោះទៅអាជ្ញាធរពាក់ព័ន្ធ សម្រាប់ធ្វើការតាមនីតិវិធីបន្ត។

# ឧបសម្ព័ន្ធទី១៖ ទម្រង់កម្រងសំណួរត្រួតពិនិត្យបឋម

| | | |
|---|---|---|
| ឈ្មោះភាគី៖ | ភេទ៖ | ថ្ងៃខែឆ្នាំកំណើត៖ |
| អាសយដ្ឋាន៖ | | |
| កាលបរិច្ឆេទ៖ | លេខទូរស័ព្ទ៖ | |
| ឈ្មោះអ្នកសម្ភាសន៍៖ | ពេលវេលា៖ | |

**សូមបញ្ជាក់ពីគោលការណ៍រក្សាការសម្ងាត់ជូនភាគី មុនពេលសួរសំណួរនិងបំពេញព័ត៌មាននៅក្នុងផ្នែកនីមួយៗខាងក្រោម៖**

**១- ប្រវត្តិនៃវិវាទ**

១.១ .តើអ្នកអាចប្រាប់ខ្ញុំបានទេអំពីវិវាទរបស់អ្នក ?តើមានអ្វីកើតឡើង ?

១.២. តើភាគីចង់បានអ្វីជាដំណោះស្រាយទៅលើវិវាទនេះ ?

| **២- វាយតម្លៃអំពីសុវត្ថិភាពរបស់ភាគី** | **ចាស/បាទ** | **ទេ** |
|---|---|---|
| ២.១ តើភាគីម្ខាងទៀតបានសម្លុតគំរាមគំហែងប្រើប្រាស់ហិង្សានិងបង្កគ្រោះថ្នាក់ដល់អ្នក ឬ អ្នកដែលជិតស្និទ្ធនឹងអ្នកដែរឬទេ ? | ☹ | ☺ |
| ២.២ តើអ្នកមានភាពភ័យខ្លាចចំពោះសុវត្ថិភាពខ្លួនឯង ឬ កូនក្នុងបន្ទុកដែរឬទេ ? | ☹ | ☺ |
| ២.៣ តើអ្នកជ្រើសរើសការសម្រុះសម្រួលនេះ ដោយស្ម័គ្រចិត្តនិងមិនមានការបង្ខិតបង្ខំ មែនទេ ? បើមិនមែន សូមបញ្ជាក់៖ ........................................................................................................ | ☺ | 😐 |

## លទ្ធផល

ប្រសិនបើក្នុងប្រអប់មានសញ្ញា ☺ **ទាំងអស់**ត្រូវបានគូស នោះការសម្រុះសម្រួល**អាចធ្វើ**ទៅបាន។

ប្រសិនបើក្នុងប្រអប់មានសញ្ញា 😐 ត្រូវបានគូស នោះត្រូវមានការប្រុងប្រយ័ត្នបន្ថែម មុនការសម្រុះសម្រួល**អាចធ្វើ**ទៅបាន។ សូមពន្យល់ទៅកាន់ភាគីពីដំណើរការសម្រុះសម្រួលនិងជម្រើសផ្សេងទៀតដែលមាន។ បន្ទាប់មក ចូរបញ្ជាក់ជាមួយភាគីថាគាត់ពិតជាយល់ច្បាស់ពីដំណើរសម្រុះសម្រួលនិងបន្តជ្រើសរើសយកការសម្រុះសម្រួលដោយស្ម័គ្រចិត្ត។ ក្នុងករណីភាគីជ្រើសរើសផ្ទុយពីនេះចូរបន្តផ្តល់ការប្រឹក្សាយោបល់និងបញ្ជូនភាគីទៅរកសេវានិងយន្តការសមស្រប។

ប្រសិនបើក្នុងប្រអប់មានសញ្ញា ☹ **ណាមួយ**ត្រូវបានគូស ការសម្រុះសម្រួល**មិនអាច**ធ្វើទៅបានទេ។ ជំនួសអោយការប្រាប់ភាគីត្រឡប់ទៅផ្ទះវិញ អ្នកសម្ភាសន៍ត្រូវជូនដំណឹងទៅអាជ្ញាធរពាក់ព័ន្ធក្នុងការចេញសេចក្តីសម្រេចរដ្ឋបាល ការរៀបចំផែនការសុវត្ថិភាព និងការអនុវត្តនូវវិធីសាស្រ្តដែលមានប្រសិទ្ធភាពផ្សេងទៀត។ល។ អ្នកសម្ភាសន៍មានកាតូកិច្ចក្នុងការផ្តល់ព័ត៌មាននិងសេវាជំនួយនានា ដល់ភាគីស្ត្រីអំពីនីតិវិធីបន្តដើម្បីធានាថា ភាគីស្ត្រីមានសុវត្ថិភាពនិងការគាំទ្រគ្រប់គ្រាន់ ស្របទៅតាមគោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រីនិងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

## សម្រាប់អ្នកសម្ភាសន៍

តើការសម្រុះសម្រួលក្នុងករណីនេះមាននីត្យានុកូលភាពនិងភាពសមស្របដែរឬទេ ? តើគោលបំណងរបស់ភាគី នៅចំនុច ១.២ អាចសម្រេចទៅបានតាមរយៈការសម្រុះសម្រួលដែរឬទេ ? តើភាគីស្ត្រីអាចធ្វើការចូលរួមក្នុងដំណើរការនេះដោយសេរី ស្មើភាព និងគ្មានការបង្ខិតបង្ខំដែរឬទេ ?

**លទ្ធផលសម្រាប់ករណីនេះ៖**...........................................................................................................

..........................................................................................................................................

..........................................................................................................................................

## ក្រសួងកិច្ចការនារី

ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣
សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ 023 880 737/882 048
882 039/882 049
ទូរសារ ៖ 023 880 737
អ៊ីម៉ែល ៖ info@mowa.gov.kh
facebook.com/mowa.gov.kh

## ក្រសួងយុត្តិធម៌

មហាវិថីសម្តេចសុធារស រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទ ៖ (+855) 23 216 322
(+855) 23 217 841
អ៊ីម៉ែល ៖ info@moj.gov.kh
គេហទំព័រ ៖ http://www.moj.gov.kh

## ក្រសួងមហាផ្ទៃ

#275 មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទ ៖ (+855) 23 721 905
(+855) 23 726 052
(+855) 23 721 190
គេហទំព័រ ៖ http://www.interior.gov.kh


បោះពុម្ពដោយ៖

ACCESS
Sustainable quality services for all

Australian Aid